ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

## សៀវភៅទស្សនាវដ្ដីចេញផ្សាយរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ១២

ខែ ៧

កុង្សីយ៍សេនាបតីបានអនុញ្ញាតហើយ
សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព.ស. ២៤៨៣
គ.ស. ១៩៤០

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# បញ្ជីរឿង


១ — ឧស្សាហកម្មជាគួបេះដូងនៃសេដ្ឋកិច្ច ខេមររង្សីរៀបរៀង. . . . . . ៣

២ — ពង្សាវតារសង្ខេបរបស់ជាតិហេប្រឺ អ្នកមហាថេរប្រែនិងរៀបរៀងពីប្រ-
វត្តិសាស្ត្រសាកលរបស់ហ្សង់វិចិត្រវ៉ាទការ . . . . . . . . . . . ១៩

៣ — និយាយពីការរចនាបែបក្រិក - ពុទ្ធសាសនានៅស្រុកគន្ធារៈ ប្រទេស
ឥណ្ឌៀ . . . . . . . . . . . . . . . . . . . . . . . ២៩

៤ — និយាយពីប្រទេសភូមាក្នុងសម័យអង់គ្លេសកាន់ការគ្រប់គ្រង . . . . ៣៣

៥ — ហោរាសាស្ត្រនឹងព្រះពុទ្ធសាសនា របស់ហ្សង់សាភនុប្រិពន្ធ (តនឹងចប់).. ៤១

៦ — ពុទ្ធប្បវត្តិចិន (តមក) . . . . . . . . . . . . . . . . . ៤៩

៧ — ប្រវត្តិមីលរេប៉ៈប្រែចេញពីភាសាទីបេតាំងមកជាភាសាបារាំងសែសរបស់
លោកសុកបាក្វត់ (តមក) . . . . . . . . . . . . . . . . . ៥៣


## រូបក្រៅរឿង


គំនូររបស់ចិន
- ១ — អំពីនាងសុជាតាថ្វាយមធុបាយាស . . . . . . . . . ១
- ២ — អំពីព្រះពោធិសត្វទ្រង់ស្រង់ទឹកជាដំបូង . . . . . . . ១៧
- ៣ — អំពីបាច់ស្មៅរបស់សុស្ថិកព្រាហ្មណ៍ . . . . . . . . ២៧
- ៤ — អំពីវិធីល្បួងនៃធីតាក្រុងមារ . . . . . . . . . . . ៣៩
- ៥ — អំពីបុត្រីនៃក្រុងមារ . . . . . . . . . . . . . . ៤៧

រចនាទីបេតាំង
- ៦ — អំពីគ្រូមីលរេប៉ៈល្បងចិត្តមីលរេប៉ៈ . . . . . . . . . ៥១

# TABLE DES MATIÈRES


| | Pages. |
|---|---|
| 1° L'industrie, cœur de l'économie sociale par KHEMARARANSI | 3 |
| 2° Histoire sommaire des Hébreux. Extraits de l'histoire générale thailandaise par LUONG VICHIT-VADAKARN traduction de Maha THÈM | 19 |
| 3° Art gréco-bouddhique du Gandhara. Extraits du catalogue du musée de Calcutta | 29 |
| 4° La Birmanie, colonie anglaise. Extrait de la revue anglaise "Géographical Magazine" | 33 |
| 5° Astrologie et Bouddhisme par LUONG SARA (suite et fin).. | 41 |
| 6° La Vie du BOUDDHA d'après des documents chinois (suite). | 49 |
| 7° La Vie de Milarépa traduit du tibétain en français par JACQUES BACOT (suite) | 53 |


HORS TEXTES :


| | | |
|---|---|---|
| Gravures chinoises... | 1° L'offrande de SUJÂTÂ | 1 |
| | 2° Le premier bain du BODHISATTVA | 17 |
| | 3° La coupe de l'herbe | 27 |
| | 4° La tentation | 39 |
| | 5° Les filles de MARA | 47 |
| Art Tibétain | 6° MILARÉPA construisant la tour demandée par MARPA | 51 |



២០ — អំពីនាងសុជាតាថ្វាយមធុបាយាស

# ឧស្សាហកម្មជាតួបេះដូងនៃសេដ្ឋកិច្ច

*របស់ខេមររដ្ឋ*

## ឧស្សាហកម្មជាតួបេះដូងនៃសេដ្ឋកិច្ច

នេះជាសេចក្ដីអធិប្បាយក្នុងកាសែតប្រជាមិត្រ ចុះថ្ងៃ ១៥-១៦ ខែ ដេសំប្រ៍ ១៩៣៨ ដែលព្រះរាជបណ្ណាល័យបានទទួល យើងយល់ថាមានប្រយោជន៍ដល់អ្នកមើលទស្សនាវដ្ដីរបស់យើងខ្លះមិនខាន ដូចមានរឿងសារសព្វខាងក្រោមនេះ:

ពាក្យថា "ឧស្សាហកម្ម" ត្រូវនឹងសព្ទភាសាអង់គ្លេសថា (Industry) សព្ទបារាំងសែសថា Industrie ដូចគ្នាដែរ សព្ទនេះប្រែថា ការប្រើកំឡាំងម៉ាស៊ីនធ្វើការបង្កើតទ្រព្យសម្បត្តិរបស់ពិភពលោក ឲ្យសមតាមបំណងនឹងសេចក្ដីត្រូវការរបស់ប្រជាជន ។

ក្នុងសម័យបុរាណ មុនកំណើតកសិកម្ម មនុស្សទាំងឡាយតែងរកចិញ្ចឹមជីវិតដោយការងារផ្សេងៗ ដូចជាជីកដំឡូង មើមឈើ ឬសឈើ នឹងចាប់សត្វស៊ីជាអាហារ ជីករូងឬចូលជ្រកតាមរអាងរហែងថ្ម យកស្បែកសត្វនឹងសំបកឈើធ្វើជាគ្រឿងស្លៀកពាក់ នេះល្មមឃើញច្បាស់ថា ឧស្សាហកម្មមានមកហើយតាំងអំពីកាលដំបូងជាអង្វែងណាស់ ។

កាលបើឧស្សាហកម្មជាគោលធំក្នុងការចិញ្ចឹមជីវិតរបស់មនុស្សដូច្នោះ ក្នុងកាលតមកប្រទេសផ្សេងៗ ដែលចាត់ចែងគ្រោងការសេដ្ឋកិច្ចក៏សម្រេចព្រមទទួលយកឧស្សាហកម្មទុកជាតួបេះដូងរបស់សេដ្ឋកិច្ចទៅ

ព្រោះមនុស្សទាំងឡាយដែលមានជីវិតរស់នៅក្នុងលោក សុទ្ធតែមានសេចក្តីត្រូវការដូចគ្នាទាំងអស់ កាលបើគ្រប់ប្រកគ្រប់អន្លើសឹងមានសេចក្តីត្រូវការកាន់តែច្រើនហើយប្លែកឡើងៗយ៉ាងនេះ ជាហេតុឲ្យមានអ្នកគិតប្រឌិតវត្ថុផ្សេងៗ ឲ្យមានលក្ខណៈពិសេសឡើង ដើម្បីឲ្យសមតាមបំណងរបស់អ្នកត្រូវការ ហេតុនេះឯងបានជាធម្មជាតិផ្សេងៗត្រូវរចនាតាក់តែងដោយកំឡាំងសតិបញ្ញារបស់មនុស្ស ។ ហេតុនេះបានជាមានអ្នកគិតបង្កើតរោងម៉ាស៊ីន (ឧស្សាហកម្ម) ឡើង ។

កាលបើមនុស្សយើងត្រូវនាំយកធម្មជាតិនិងវត្ថុផ្សេងៗមកប្រឌិតធ្វើឡើង ហើយផ្សាយដល់មនុស្សលោកដែលមានសេចក្តីត្រូវការរកទីបំផុតគ្មានដូច្នេះហើយ ឧស្សាហកម្មក៏កាន់តែបណ្តុះបណ្តាលបង្កើតរបស់ចំឡែកៗឲ្យមានច្រើនឡើងជាអនេកប្រការ ដូចជាអគ្គិសនី, ទឹកកក, ម៉ាស៊ីនចៀង, វិទ្យុ, រថយន្ត, រថចម្បាំង, រថភ្លើង, កប៉ាល់, យន្តហោះនិងបណ្តានានាវត្ថុជាអនេកប្រការដទៃទៀត ហើយឧស្សាហកម្មនៅបង្កើតផលានុផលឲ្យដល់ប្រទេសផ្សេងៗជាច្រើនប្រការដោយឡែកទៀត ហេតុនេះហើយបានជាឧស្សាហកម្មផ្សាយចេញទៅគ្រប់ៗប្រទេសក្នុងលោក ។

ជនជាតិជប៉ុនមានគំនិតគិតទឹកដល់ដំឡៃនៃឧស្សាហកម្មដែលប្រទេសទិសខាងលិចបណ្តាលឲ្យកើតឡើងជាទីអស្ចារ្យណាស់ កប់តាំងអំពី

ព្រោះមនុស្សទាំងឡាយដែលមានជីវិតរស់នៅក្នុងលោក សុទ្ធតែមានសេចក្ដីត្រូវការដូចគ្នាទាំងអស់ កាលបើគ្រប់ប្រក គ្រប់អន្លើសឹងមានសេចក្ដីត្រូវការកាន់តែច្រើនហើយប្លែកឡើងៗយ៉ាងនេះ ជាហេតុឲ្យមានអ្នកគិតប្រឌិតវត្ថុផ្សេងៗ ឲ្យមានលក្ខណៈវិសេសឡើង ដើម្បីឲ្យសមតាមបំណងរបស់អ្នកត្រូវការ ហេតុនេះឯងបានជាធម្មជាតិផ្សេងៗត្រូវរចនាតាក់តែងដោយកំឡាំងសតិបញ្ញារបស់មនុស្ស ។ ហេតុនេះបានជាមានអ្នកគិតបង្កើតពេងម៉ាស៊ីន (ឧស្សាហកម្ម) ឡើង ។

កាលបើមនុស្សយើងត្រូវនាំយកធម្មជាតិនិងវត្ថុផ្សេងៗមកប្រឌិតធ្វើឡើង ហើយផ្សាយដល់មនុស្សលោកដែលមានសេចក្ដីត្រូវការរកទីបំផុតគ្មានដូច្នេះហើយ ឧស្សាហកម្មក៏កាន់តែបណ្ដុះបណ្ដាលបង្កើតរបស់ចំឡែកៗឲ្យមានច្រើនឡើងជាអនេកប្រការ ដូចជាអគ្គិសនី, ទឹកកក, ម៉ាស៊ីនច្រៀង, វិទ្យុ, រថយន្ត, រថចម្បាំង, រថភ្លើង, កប៉ាល់, យន្តហោះនិងបណ្ដានានាវត្ថុជាអនេកប្រការដទៃទៀត ហើយឧស្សាហកម្មនៅបង្កើតផលានុផលឲ្យដល់ប្រទេសផ្សេងៗជាច្រើនប្រការដោយឡែកទៀត ហេតុនេះហើយបានជាឧស្សាហកម្មផ្សាយចេញទៅគ្រប់ៗប្រទេសក្នុងលោក ។

ជនជាតិជប៉ុនមានគំនិតគិតទឹកដល់ដំឡៃនៃឧស្សាហកម្មដែលប្រទេសទិសខាងលិចបណ្ដាលឲ្យកើតឡើងជាទីអស្ចារ្យណាស់ រាប់តាំងអំពី

ព. ស. ២៤៩៧ ជាដើមមក ជប៉ុនខំទំនុកបម្រុងការឧស្សាហកម្មយ៉ាងសំបើម យុវជនដែលមានចំណេះល្មមធ្វើការងារបាន ក៏ត្រូវបាត់បញ្ជូនទៅហាត់ធ្វើការងារតាមរោងឧស្សាហកម្មផ្សេងៗ មានកំណត់ ៤ ឆ្នាំ កាលបើស្ទាត់ជំនាញហើយ ទើបរដ្ឋបាលចំណាយប្រាក់តាំងរោងឧស្សាហកម្មផ្សេងៗឡើង ហើយជួលក្មេងក្រមុំកំឡោះអស់នោះមកធ្វើការ ៗ ឯការបើកប្រាក់ឈ្នួលធ្វើការនេះ រដ្ឋបាលមិនបើកឲ្យតាមកំណត់ទេ ទុកឲ្យនៅសល់ខ្លះ កាលណាសន្សំបានច្រើនទើបគាត់ឲ្យពួកនេះចូលហ៊ុនគ្នាតាំងរោងឧស្សាហកម្ម ហើយគាត់ចែងការងារដោយខ្លួនឯង ៗ ពជការបែបនេះ ទើបចំជាពជការទំនុកបម្រុងពស្ត្ររបស់គេមែន មានទំនងដូចឪពុកម្ដាយទំនុកបម្រុងកូន ឬគ្រូទំនុកបម្រុងសិស្ស ដោយមេត្រីចិត្តអាណិតអាសូរពិតប្រាកដមែន ៗ

តមកប្រាក់រៀលយេនរបស់ជប៉ុនចេញបាកមាត្រាមាស (មកកាន់មាត្រាប្រាក់វិញ). បណ្ដាកសិករ (អ្នកស្រែចំការ) ត្រូវទទួលភារៈយ៉ាងធ្ងន់ ទើបរដ្ឋបាលបានចូលជួយដោះកុន ហើយជួយទំនុកបម្រុងឋានៈកសិករឲ្យបានគ្រាន់បើឡើង ដោយកិច្ចការខាងឧស្សាហកម្ម សូម្បីក្នុងដែនមញ្ជូកោ ជប៉ុនក៏នាំយកនយោបាយទំនុកបំរុងឧស្សាហកម្មផ្សេងៗទៅប្រើយ៉ាងខ្នងឃ្លាត ទើបធ្វើឲ្យជំនួញជប៉ុនមានកម្លាំងអាចរកយកកំបាយផ្សារមញ្ជូកោបានសំរេច ៗ

ក្នុងបច្ចុប្បន្ននេះ ប្រទេសជប៉ុនមានរោងឧស្សាហកម្មច្រើនបែបណាស់ ចំពោះកន្លែងដែលប្រើគ្រឿងចក្រ ( ម៉ាស៊ីន ) នោះមានចំនួនដល់ទៅ៤៥.១៤១ កន្លែង ដែលប្រើកម្លាំងមនុស្សធ្វើការចំនួន ១០.៣៩២ កន្លែង កាលពីដើម ជប៉ុនជាកូនជំនួញរបស់ឦរុប តែដល់ឥឡូវនេះជប៉ុនត្រឡប់ជាមេជំនួញរបស់ឦរុបវិញ ហើយជាប្រទេសដែលមានរោងឧស្សាហកម្មច្រើនបំផុតនៅទិសខាងកើតនេះ ។

ភូមិសាស្រ្តពាណិជ្យក្នុងបច្ចុប្បន្ននេះសំដែងឲ្យឃើញថា អាល្លឺ-ម៉ង់មានគ្រោងការទំនុកបំរុងការឧស្សាហកម្មច្រើនជាងអ្វីៗដទៃទៀតក្នុងប្រទេសរបស់ខ្លួន លើកលែងតែប្រទេសអង់គ្លេសមួយចេញ អាល្លឺម៉ាញជាប្រទេសដែលមានរោងឧស្សាហកម្មច្រើនបំផុត ដូចជារោងតម្បាញមានដល់ទៅ ១២២.៩៨៦ រោង រោងធ្វើដែកមាន ១៥០.២៩៩ រោង រោងធ្វើក្រដាសមាន ៣៥.៧៦៥ រោង រោងអារឈើ ២១៩.៣៣៥ រោង រោងធ្វើបាន ៣៤.៨៩៨ រោង រោងចក់លោហធាតុ ១.៩២៤ កន្លែង រោងធ្វើសុរា ៣៨.១៨៦ រោង រោងធ្វើស្ករ ២៣៣ រោង ។ល។ រួមរោងឧស្សាហកម្មផ្សេងៗ ទូទៅមានចំនួនមិនតិចជាង ៦០៤.៥៩៧ រោង ហេតុនេះហើយបានជាអាល្លឺម៉ង់ក្នុងសម័យឥឡូវនេះ រឹងប៉ឹងខ្លាំងពូកែជាងអាល្លឺម៉ង់សម័យមុន គ.ស. ១៩១៤ មានទំនងដូច្នេះពិតៗ ។

ក្នុងបច្ចុប្បន្ននេះ ប្រទេសជប៉ុនមានរោងឧស្សាហកម្មច្រើនបែបណាស់ ចំពោះកន្លែងដែលប្រើគ្រឿងចក្រ ( ម៉ាស៊ីន ) នោះមានចំនួនដល់ទៅ ៤៥.១៤១ កន្លែង ដែលប្រើកម្លាំងមនុស្សធ្វើការចំនួន ១០.៣៩២ កន្លែង កាលពីដើម ជប៉ុនជាកូនជំនួញរបស់ឦរុប តែដល់ឥឡូវនេះជប៉ុនត្រឡប់ជាមេជំនួញរបស់ឦរុបវិញ ហើយជាប្រទេសដែលមានរោងឧស្សាហកម្មច្រើនបំផុតនៅទិសខាងកើតនេះ ។

ភូមិសាស្ត្រពាណិជ្យក្នុងបច្ចុប្បន្ននេះសំដែងឲ្យឃើញថា អាល្លឺម៉ង់មានគ្រោងការទំនុកបំរុងការឧស្សាហកម្មច្រើនជាងអ្វីៗដទៃទៀតក្នុងប្រទេសរបស់ខ្លួន លើកលែងតែប្រទេសអង់គ្លេសមួយចេញ អាល្លឺម៉ាញជាប្រទេសដែលមានរោងឧស្សាហកម្មច្រើនបំផុត ដូចជារោងតម្បាញមានដល់ទៅ ១២២.៩៨៦ រោង រោងធ្វើដែកមាន ១៥០.២៩៩ រោង រោងធ្វើក្រដាសមាន ៣៥.៧៦៥ រោង រោងអារឈើ ២១៩.៣៣៥ រោង រោងធ្វើបាន ៣៤.៨៩៨ រោង រោងជីកលោហធាតុ ១.៩២៤ កន្លែង រោងធ្វើស្រា ៣៨.១៨៦ រោង រោងធ្វើស្ករ ២៣៣ រោង ។ល។ រួមរោងឧស្សាហកម្មផ្សេងៗ ទៅមានចំនួនមិនតិចជាង ៦០៤.៥៩៧ រោង ហេតុនេះហើយបានជាអាល្លឺម៉ង់ក្នុងសម័យឥឡូវនេះ រឹងប៉ឹងខ្លាំងពូកែជាងអាល្លឺម៉ង់សម័យមុន គ.ស. ១៩១៤ មានទំនងដូច្នេះពិតៗ ។

ចំណែកឯប្រទេសអាមេរិកនោះមានកេរ្តិ៍ឈ្មោះល្បីល្បាញខាងសំបូរសេដ្ឋគហបតី  មានអ្នកមានធនធានច្រើនជាងប្រទេសឯទៀត ។ ក៏ព្រោះមានឧស្សាហកម្មច្រើនហើយមានការចេញបាច់គ្នាជាយ៉ាងចំណាប់ រវាងពួកកស្តុទីងកជការ ។ លោករូស្សវែលកាលមិនទាន់បានធ្វើជាប្រធានាធិបតីនៃប្រទេសអាមេរិកនៅឡើយ លោកបានពោលថា កាលពីដើមប្រទេសអាមេរិកជាកូនបំណុលរបស់អឺរ៉ុប តែតមកក្រោយមហាសង្គ្រាម ប្រទេសអឺរ៉ុបត្រឡប់ជាកូនបំណុលអាមេរិកវិញ ហេតុទាំងនេះព្រោះប្រទេសរបស់យើងបានលូកតាប់គោលសំខាន់របស់សេដ្ឋកិច្ចបានថា ការឧស្សាហកម្មជាគោលធំបំផុត ។ លុះលោករូស្សវែលបានធ្វើជាប្រធានាធិបតីនៃប្រទេសអាមេរិកហើយ ទើបលោកខំទំនុកបំរុងឧស្សាហកម្មឲ្យកាន់តែរីកធំឡើង ឲ្យមានចំនួនកាន់តែច្រើនឡើងទៀតផង ។ មានដំណឹងថ្មីៗ ក្នុងកាលឥឡូវនេះថា ពេលឧស្សាហកម្មមួយ (អាមេរិក) កំពុងតាក់តែងកិច្ចការឲ្យកាន់តែរីកធំឡើង ព្រោះបានគិតប្រឌិតគុណភាពរបស់ស្រូវឲ្យបានវិសេសឡើងទៀត ទើបមានមនុស្សនិយមបរិភោគបាយជំនួសនំបុ័ងដល់ទៅ ៣០ % ។

ហ្វីលីពីនជាកោះនៅក្នុងសមុទ្រប៉ាស៊ីហ្វិក មុននឹងបានជារដ្ឋឥស្សរៈ អាមេរិកាំងទឹកកន្ទល់អំពីសេដ្ឋកិច្ចរបស់កោះនេះណាស់ លុះហ្វីលីពីនញែក

ដាច់ពីប្រទេសអាមេរិក សេដ្ឋកិច្ចរបស់ហ្វីលីពីនត្រឡប់ជាស្ទុះចំរើនឡើងវិញ ព្រោះបែរមកយកចិត្តទុកដាក់ទំនុកបំរុងឧស្សាហកម្ម តាមធម្មតាប្រទេសហ្វីលីពីនមានធម្មជាតិវត្ថុសព្វគ្រប់ហើយ លុះបានតាំងរោងឧស្សា-ហកម្មឡើង មិនលំបាកនឹងរកទិញធម្មជាតិវត្ថុអំពីប្រទេសដទៃឡើយ ដូចរោងធ្វើម្សៅអំពីដំឡូងបារាំង រោងមាស៊ីនកៃប្រែអល្កុលជាអេស្សង់ជាដើមៗ

ប្រទេសចិន មុននឹងទៅសេពគប់នឹងជនជាតិទិសខាងលិច ចិនប្រកាន់កសិកម្មជាបង ឧស្សាហកម្មជាប្អូនពៅ ទើបមានការទំនុកបំរុងតែបន្តិចបន្តួច ហេតុនេះបានជាសេដ្ឋកិច្ចរបស់ចិនក្នុងអតីតកាលមិនសូវចំរើនឡើយ តមកចិនបានសេពគប់នឹងជនជាតិទិសខាងលិច ស្រាប់តែមានជំនួញផ្សេងៗរបស់នានាប្រទេសហៀហូរចូលមកកាន់ប្រទេសយ៉ាងសំបើម ទើបចិនដឹងខ្លួនថាដល់ពេលវេលាដែលត្រូវតែកែប្រែធម្មជាតិវត្ថុខាងក្នុងស្រុកឲ្យកើតជំនួញសព្វគ្រប់ប្រើប្រាស់ក្នុងស្រុកហើយ តអំពីនោះមកទើបចិនខំទំនុកបំរុងឧស្សាហកម្មយ៉ាងខ្មីឃ្មាត ក្នុងសម័យដែលលោកកាំងជិងវៃជានាយករដ្ឋមន្ត្រី លោកមានប្រសាសន៍ថា "ជាតិចិននឹងផុតរបូតពីចំណីអាហារក្នុងផ្លូវសេដ្ឋកិច្ចទៅបាន ដោយការទំនុកបំរុងឧស្សាហកម្មខាងក្នុងប្រទេសឲ្យចំរើនឡើង" ហេតុដូច្នេះបានជាឥឡូវនេះចិនមិនពាញ់អ្នកណាទេ ក្នុងផ្លូវចំណាយចំណូលខាងជំនួញ ៗ ជំនួញដែលចំណាយចេញ

ដាច់ពីប្រទេសអាមេរិក សេដ្ឋកិច្ចរបស់ហ្វីលីពីនត្រឡប់ជាស្ទុះចំរើនឡើងវិញ ព្រោះបែរមកយកចិត្តទុកដាក់ទំនុកបំរុងឧស្សាហកម្ម តាមធម្មតាប្រទេសហ្វីលីពីនមានធម្មជាតិវត្ថុសព្វគ្រប់ហើយ លុះបានតាំងរោងឧស្សាហកម្មឡើង មិនលំបាកនឹងរកទិញធម្មជាតិវត្ថុអំពីប្រទេសដទៃឡើយ ដូចរោងធ្វើម្សៅអំពីដំឡូងបារាំង រោងម៉ាស៊ីនកែប្រែអល្កុលជាអេស្សង់ជាដើមៗ

ប្រទេសចិន មុននឹងទៅសេពគប់នឹងជនជាតិទិសខាងលិច ចិនប្រកាន់កសិកម្មជាច្បង ។ ឧស្សាហកម្មជាប្អូនទៅ ទើបមានការទំនុកបំរុងតែបន្តិចបន្តួច ហេតុនេះបានជាសេដ្ឋកិច្ចរបស់ចិនក្នុងអតីតកាលមិនសូវចំរើនឡើយ តមកចិនបានសេពគប់នឹងជនជាតិទិសខាងលិច ស្រាប់តែមានជំនួញផ្សេងៗរបស់នានាប្រទេសហៀរហូរចូលមកកាន់ប្រទេសយ៉ាងសំបើម ទើបចិនដឹងខ្លួនថាដល់ពេលវេលាដែលត្រូវតែកែប្រែធម្មជាតិវត្ថុខាងក្នុងស្រុកឲ្យកើតជំនួញសព្វគ្រប់ប្រើប្រាស់ក្នុងស្រុកហើយ តអំពីនោះមកទើបចិនខំទំនុកបំរុងឧស្សាហកម្មយ៉ាងខ្មីឃ្មាត ក្នុងសម័យដែលលោកក៉ងជិនវ៉ៃជានាយករដ្ឋមន្ត្រី លោកមានប្រសាសន៍ថា "ជាតិចិននឹងផុតរបូតពីចំណីអាហារក្នុងផ្លូវសេដ្ឋកិច្ចទៅបាន ដោយការទំនុកបំរុងឧស្សាហកម្មខាងក្នុងប្រទេសឲ្យចំរើនឡើង" ហេតុដូច្នេះបានជាឥឡូវនេះចិនមិនទាញអ្នកណាទេ ក្នុងផ្លូវចំណាយចំណូលខាងជំនួញ ។ ជំនួញដែលចំណាយចេញ

ទៅក្រៅប្រទេសក៏មានច្រើនយ៉ាង ដូចគ្រឿងកំប៉ុង ស៊ឹកកែត ផារី ល្ង សណ្តែកផ្សេងៗ ជាដើម ។

ប្រទេសអង់គ្លេស ជាប្រទេសដែលខំទំនុកបំរុងឧស្សាហកម្មពេញទី កប់តាំងអំពីម៉ោង ៦ ព្រឹកជាដើមទៅ ផ្សែងភ្លើងដែលចេញអំពីបំពង់ភ្លើង រោងធ្វើការផ្សេងៗហុយទ្រលោមរួមជាដុំឡើងទៅលើមេឃ គ្របឃុំកោះ អង់គ្លេសទាំងមូល ព្រោះអង់គ្លេសមានរោងឧស្សាហកម្មច្រើនបំផុតក្នុង លោក មានចំនួនដល់ទៅ ៧៦៨.០២៨ កន្លែង មានខែត្រខ្លះប្រជាជន ទាំងអស់រកស៊ីតែក្នុងរោងឧស្សាហកម្មក៏មាន ។

បារាំងសែសជាប្រទេស ១ ទៀត ដែលមានរោងឧស្សាហកម្មសំបើម ណាស់ដែរ សព្វថ្ងៃជាម្ចាស់ផ្សារប៉ែកខាងសុក, សំពត់, កប្បាស, ស្រា ទំពាំងជូរក្នុងលោក ។ លោកឡាវ៉ាល់ជានាយករដ្ឋមន្ត្រីសព្វថ្ងៃនេះ ក៏ ផ្តើមតាក់តែងកែប្រែឧស្សាហកម្មមុនអ្វីទៀតទាំងអស់ មិនយូរប៉ុន្មាន រោង តម្បាញសំពត់នៅស្រុករៀម, លូបេស៍, រោងត្បាញសូត្រលីយ៉ុង, រោង ត្បាញកប្បាសនៅខែត្រនរម៉ង់ឌី រោងធ្វើគ្រឿងចក្រនៅស្រុកសាំង-តេដៃន, រោងធ្វើទឹកអប់នៅក្រុងប៉ារីស តែនីមួយៗធំសំបើមអស្ចារ្យ លោកឡាវ៉ាល់ គួរពេបថា ជានាយករដ្ឋមន្ត្រីរបស់បារាំងសែស ដែលបាន ទៅធ្វើពិធីបើករោងឧស្សាហកម្មច្រើនជាងគេបង្អស់ ។

ចំណែកឯប្រទេសឥណ្ឌាមានដីរាបជាទីទំនាបច្រើនអន្លើ ដូចតាមដងទន្លេសិន្ធុជាដើម តាមកន្លែងអស់នេះជាទីប្រជុំអ្នកស្រែចំការ មានការដាំដំណាំផ្សេងៗជាចំនួនច្រើន ឥណ្ឌាបានយកចិត្តទុកដាក់ទំនុកបំរុងការកសិកម្មនៅចំណែកនេះមកយូរអង្វែងហើយ ទុកជាធ្វើដូច្នេះក៏ដោយ ឥណ្ឌាក៏នៅតែមិនចំរើនឡើងទាន់កាលសម័យ ។

លុះអង់គ្លេសចូលទៅគ្រប់គ្រងឥណ្ឌាក្នុង ព.ស.២៤០០ អង់គ្លេសបាននាំយកនយោបាយទំនុកបំរុងការឧស្សាហកម្មដែលច្រើនបានផលល្អក្នុងប្រទេសខ្លួនមកប្រើក្នុងប្រទេសឥណ្ឌាដែរ តអំពីនោះមកឥណ្ឌាក៏ចាត់ចែងសាងផ្លូវរថភ្លើង, សាងថ្នល់, ទំនប់ទឹក, ជីកព្រែក, បង្កើតរោងត្បាញសំពត់, រោងធ្វើបារក្រថៅ, រោងចម្រាញ់ប្រេង ហើយថែមទាំងមានរោងធ្វើក្រដាសយ៉ាងធំសំបើមបំផុត ក្នុង១ថ្ងៃៗអាចធ្វើក្រដាសចេញផ្សាយប្រហែល ២០ដល់២៥តោន បើទឹងគិតជាប្រាក់រៀលយើងនេះប្រ-មាណ ២.០០០.០០០ រៀល (ក្នុង១ថ្ងៃៗ) ដោយហេតុឥណ្ឌាខំទំនុកបំរុងឧស្សាហកម្មនេះឯង ទើបមានជំនួញច្រើនយ៉ាងច្រើនប្រការផ្សាយទៅលក់នៅតាមប្រទេស ប្រទេសកម្ពុជាយើងនេះក៏ទទួលទំនិញពីប្រទេសឥណ្ឌាច្រើនយ៉ាងដែរ ដូចជាបារស្រូវ សំពត់ព្រែ ខៀន ជាដើម ។

ប្រទេសរុស្ស៊ី កាលនៅក្នុងសម័យចក្រពត្តិសានិត្យនោះឧស្សា-ហកម្មប្រទេសរុស្ស៊ីមានសេចក្តីចំរើនគួរសមដែរ មានរោងប្រកបការ

ចំណែកឯប្រទេសឥណ្ឌាមានដីកបជាទីទំនាបច្រើនអន្លើ ដូចតាមដងទន្លេសិន្ធុជាដើម តាមកន្លែងអស់នេះជាទីប្រជុំអ្នកធ្វើស្រែចំការ មានការដាំដំណាំផ្សេងៗជាចំនួនច្រើន ឥណ្ឌាបានយកចិត្តទុកដាក់ទំនុកបំរុងការកសិកម្មនៅចំណែកនេះមកយូរអង្វែងហើយ ទុកជាធ្វើដូច្នេះក៏ដោយ ឥណ្ឌាក៏នៅតែមិនចំរើនឡើងទាន់កាលសម័យ ។

លុះអង់គ្លេសចូលទៅគ្រប់គ្រងឥណ្ឌាក្នុង ព.ស.២៤០០ អង់គ្លេសបាននាំយកនយោបាយទំនុកបំរុងការឧស្សាហកម្មដែលច្រើនបានផលល្អក្នុងប្រទេសខ្លួនមកប្រើក្នុងប្រទេសឥណ្ឌាដែរ តអំពីនោះមកឥណ្ឌាក៏ចាត់ចែងសាងផ្លូវរថភ្លើង, សាងថ្នល់, ទំនប់ទឹក, ជីកព្រែក, បង្កើតរោងត្បាញសំពត់, រោងធ្វើបាវក្រចៅ, រោងចម្រាញ់ប្រេង ហើយថែមទាំងមានរោងធ្វើក្រដាសយ៉ាងធំសំបើមបំផុត ក្នុង១ថ្ងៃៗអាចធ្វើក្រដាសចេញផ្សាយប្រហែល២០ដល់២៥តោន បើនឹងគិតជាប្រាក់រៀលយើងនេះប្រមាណ២.០០០.០០០រៀល (ក្នុង១ថ្ងៃៗ) ដោយហេតុឥណ្ឌាទំនុកបំរុងឧស្សាហកម្មនេះឯង ទើបមានជំនួញច្រើនយ៉ាងច្រើនប្រការផ្សាយទៅលក់នៅតាមប្រទេស ប្រទេសកម្ពុជាយើងនេះក៏ទទួលទំនិញពីប្រទេសឥណ្ឌាច្រើនយ៉ាងដែរ ដូចជាបាវស្រូវ សំពត់ព្រែ ខៀន ជាដើម ។

ប្រទេសរុស្ស៊ី កាលនៅក្នុងសម័យចក្រពត្តិសានិកូឡាសនោះឧស្សាហកម្មប្រទេសរុស្ស៊ីមានសេចក្ដីចំរើនគួរសមដែរ មានរោងប្រកបការ

ឧស្សាហកម្មជាច្រើនអន្លើ ព្រោះរុស្ស៊ីមានផែនដីដីជាតិជាច្រើនតំបន់សម្រាប់ប្រកបកិច្ចកសិកម្ម ទើបមិនបាច់កង្វល់វិតក្កអំពីសេចក្ដីខ្វះខាតដោយវត្ថុធម្មជាតិ ប៉ុន្តែតាំងពីចាញ់សង្គ្រាមជប៉ុនក្នុង ព.ស. ២៤៤៨ រុស្ស៊ីក៏កាន់តែខំប្រឹងខំទំនុកបំរុងសេដ្ឋកិច្ចចំពោះចំណែកដែលខូចខាតទៅក្នុងសង្គ្រាមធ្វើឲ្យមានពេញលេញឡើងវិញ ហើយខំប្រឹងតាក់សាងរោងឧស្សាហកម្មផ្សេងៗជាច្រើនតំបន់ ៗ តមកកាលវង្សស្ដេចរ៉ូម៉ាណូហ្វដល់នូវសេចក្ដីវិនាស ទាំងផែនដីក៏កើតចលាចលនាំឲ្យរំជួលដល់សេដ្ឋកិច្ចរបស់ស្រុកយ៉ាងខ្លាំង ៗ បន្ទាប់អំពីនោះមក រុស្ស៊ីក៏ធ្លាក់នៅក្រោមអំណាចរបស់ស្តាលីនដោយដាច់ខាត មាននយោបាយប្រឹងកសាងប្រទេសជាតិកាន់តែខ្លាំងឡើង មានការទំនុកបំរុងឧស្សាហកម្មជាដើម ដោយយល់ច្បាស់ថា សេដ្ឋកិច្ចរបស់ប្រទេសនេះឯង ដែលជាជីវិតវិញ្ញាណរបស់កងទ័ពពួកក្រហម (កុម្មុយនិស្ដ៍) បណ្ដាជំនួញផ្សេងៗដែលចាត់ប្រឌិតឡើងក្នុងប្រទេសរុស្ស៊ី ហើយផ្ញើទៅចំណាយនៅប្រទេសផ្សេងៗ វេលានេះមានប្រមាណ ៩៨% ។

ក្រៅអំពីនេះ នៅមានប្រទេសផ្សេងៗទៀតជាច្រើនដែលចិញ្ចឹមជាតិរបស់ខ្លួនដោយឧស្សាហកម្មសុទ្ធៗ ដោយហេតុលក្ខណៈរបស់ភូមិប្រទេសនឹងចាត់ចែងធ្វើការយ៉ាងដទៃទៀតពុំបាន ដូចប្រទេស អឡាស្កា ភូមិប្រទេសនេះច្រើនតែពាសពេញទៅដោយទឹកកក ដាំដំណាំមិនកើតល្អ

តែគ្រោះល្អណាស់ ប្រទេសនេះមានលោហធាតុបរិបូណ៌ ទើបចាត់ចែងធ្វើតែឧស្សាហកម្មដោយពេញដៃ ធ្វើលោហធាតុផ្សាយចេញជាជំនួញក្នុង១ឆ្នាំៗ ប្រហែល ១០ លានរៀល ធ្វើស្បែកសត្វដែល (នៅតាមទឹកកក ដូចជាហ្វូក) ប្រឌិតធ្វើជាជំនួញចំណាយចេញទៅក្រៅមិនតិចជាង ១សែនស្បែក ក្រៅអំពីនេះនៅមានកំឡាំងសាងផ្លូវរទេះភ្លើងមានចម្ងាយដល់ទៅ ៥០០ម៉ៃល៍ (១ម៉ៃល៍ប្រហែល១គីឡូកន្លះ) តាំងអំពីមាត់សមុទ្ររហូតដល់ផ្សារជំនួញ ហេតុនេះឯងបានជា អឡាស្កា មិនដុនដាបទ័លក្រប៉ុន្មានទេ ។

នរវ៉ែស៍ ជាប្រទេសមានដីលិចទឹកសមុទ្រជាចំនួនច្រើន ដាំអ្វីមិនកើត ៩៤ % ចំណែកដែលសេសសល់ទៀត ៦ % ក៏ដាំបានតែស្រូវប៊ើ, ដំឡូងបារាំង ហេតុនេះបានជាអ្នកស្រុកនរវ៉ែស៍ យល់ថាបើមិនរករកឧស្សាហកម្មខ្លះជាអត់ស្លាប់មិនខាន ទុកជាត្រូវទិញធម្មជាតិវត្ថុមកគិតប្រឌិតធ្វើជាជំនួញក៏ដោយ ក៏នៅតែគ្រាន់បើជាងទិញទំនិញដែលគេសម្រេចរបស់គេស្រាប់ដែរ មិនយូរប៉ុន្មាន ប្រទេសនរវ៉ែស៍ ក៏មានជំនួញដែលប្រឌិតសម្រេចហើយ នាំទៅចំណាយនៅប្រទេសផ្សេងៗជាច្រើនមុខ ដូចត្រីខកំប៉ុង, ក្រដាស, ប៊ើរ, ខ្លាញ់ត្រីជាដើម ។

តាមដែលពោលមកខាងលើនេះ យើងឃើញច្បាស់ថា មិនមានប្រទេសណាក្នុងលោកដែលនឹងការដំបង្អង់ក្នុងការទំនុកបំរុងឧស្សាហកម្មឡើយ

តែគ្រោះល្អណាស់ ប្រទេសនេះមានលោហធាតុបរិបូណ៌ ទើបចាត់ចែង ធ្វើតែឧស្សាហកម្មដោយពេញដៃ ធ្វើលោហធាតុផ្សាយចេញជាជំនួញ ក្នុង១ឆ្នាំៗ ប្រហែល ១០ លានរៀល ធ្វើស្បែកសត្វដែល (នៅតាមទឹកកក ដូចជាហ្វូក) ប្រឌិតធ្វើជាជំនួញចំណាយចេញទៅក្រៅមិនតិចជាង ១ សែនស្បែក ក្រៅអំពីនេះនៅមានកំឡាំងសាងផ្លូវរទេះភ្លើងមានចម្ងាយដល់ទៅ ៥០០ម៉ែល (១ម៉ែលប្រហែល១គីឡូកន្លះ) តាំងអំពីមាត់សមុទ្ររហូតដល់ផ្សារជំនួញ ហេតុនេះឯងបានជា អឡាស្កា មិនដុនជាបទ័លក្រប៉ុន្មានទេ ។

នរវ៉េស្ស៍ ជាប្រទេសមានដីលិចទឹកសមុទ្រជាចំនួនច្រើន ដាំអ្វីមិនកើត ៩៤ % ចំណែកដែលសេសសល់ទៀត ៦ % ក៏ដាំបានតែស្រូវបេ៊ី, ដំឡូងបារាំង ហេតុនេះបានជាអ្នកស្រុកនរវ៉េស្ស៍ យល់ថាបើមិនរករកឧស្សាហកម្មនេះជាអត់ស្លាប់មិនខាន ទុកជាត្រូវទិញធម្មជាតិវត្ថុមកគិតប្រឌិតធ្វើជាជំនួញក៏ដោយ ក៏នៅតែគ្រាន់បើជាងទិញទំនិញដែលគេសម្រេចរបស់គេស្រាប់ដែរ មិនយូរប៉ុន្មាន ប្រទេសនរវ៉េស្ស៍ ក៏មានជំនួញដែលប្រឌិតសម្រេចហើយ នាំទៅចំណាយនៅប្រទេសផ្សេងៗជាច្រើនមុខ ដូចត្រីខកំប៉ុង, ក្រដាស, ប៊ើរ, ខ្លាញ់ត្រីជាដើម ។

តាមដែលពោលមកខាងលើនេះ យើងឃើញច្បាស់ថា មិនមានប្រទេសណាក្នុងលោកដែលទឹងការងបង្អង់ក្នុងការទំនុកបំរុងឧស្សាហកម្មឡើយ

គ្រប់ ៗ ប្រទេសសឹងមានយោបល់ត្រូវគ្នា ក្នុងការយឹតយកនយោបាយទំនុកបំរុងសេដ្ឋកិច្ចរបស់ប្រទេស ដោយការបង្កើតឲ្យមានឧស្សាហកម្មច្រើនឡើង សូម្បីប្រទេសកសិកម្ម ដូចជាអាមេរិក, ឥណ្ឌូ, ចិន, ហ្វីលីពីន ជាដើម ក៏គេងាកទៅរកឧស្សាហកម្ម ដើម្បីទំនុកបំរុងប្រទេសឲ្យបានចំរើនជាប់ ៗ ចុះបើប្រទេសដែលមានធម្មជាតិវត្ថុបរិបូណ៌ស្រាប់ផងនឹងមានចំណេញច្រើនជាងប្រទេសដែលទិញធម្មជាតិវត្ថុពីក្រៅមកធ្វើរបស់ផ្សេងៗជាមិនខាន ។

បើយើងងាកមកពិនិត្យស្រុកយើងខាងក្រុងកម្ពុជាវិញ នឹងឃើញថាប្រទេសនេះមានធម្មជាតិវត្ថុបរិបូណ៌ ចាត់បញ្ជូនទៅចំណាយប្រទេសក្រៅៗ ជាចំនួនច្រើនរាល់ៗឆ្នាំ តែមិនសូវមានរោងឧស្សាហកម្មតាំងឡើងសោះ ដោយហេតុខ្វះខាតបច្ច័យជាគ្រឿងទំនុកបំរុង ព្រមទាំងកស្ត្រមាននិស្ស័យសន្ទោសជាច្រើនផង ប៉ុន្តែកិច្ចការទំនងនេះ ប្រសិនបើយើងគិតតាំងជាសមាគមបង្កើតរោងឧស្សាហកម្មអ្វីមួយឡើង ឲ្យឃើញថាជាស្នាដៃរបស់ជនជាតិខ្មែរក៏គង់កើតឡើងបានមិនខានទេ ។

**ខេមរង្សី**



២១ — អំពីព្រះពោធិសត្វទ្រង់ស្រង់ទឹកដំបូង

# ពង្សាវតារសង្ខេប

របស់

# ជាតិហេប្រឺ

(Hébreux)

ការសិក្សាពង្សាវតាររបស់ជនជាតិនេះ មានប្រយោជន៍ ២ ប្រការ គឺ ១ – ធ្វើឲ្យយើងបានដឹងពង្សាវតាររបស់សាសនាគ្រិស្ត ទុកជាយើងមិនមែនជាអ្នកកាន់សាសនានេះ ក៏មិនជាការធ្ងន់ស្រាលអ្វីដែរ តែជាការបន្ថែមចំណេះវិជ្ជារបស់យើងឲ្យកាន់តែចំរើនកើនឡើងទៀតទេតើ ហេតុនេះ ទើបយើងឃើញថា យើងជាអ្នកកាន់សាសនាត្រូវតែចេះដឹងលទ្ធិសាសនាផ្សេងៗជាគ្រឿងប្រដាប់សតិបញ្ញារបស់យើងឲ្យកាន់តែរីកធំឡើង ៗ ២ – ធ្វើឲ្យយើងបានដឹងស្គាល់លក្ខណៈរបស់មនុស្សសម័យបុរាណ ដែលរួបរួមគ្នាជាពួកជាក្រុម ហើយនាំគ្នាត្រេចរង្គាត់ទៅកាន់ទីតំបន់ផ្សេងៗ ហើយបានជួបប្រទះនឹងតំបន់ដែលមានផលដីជាតិល្អក៏តាំងទីកន្លែងនៅទីនោះជាប់ជានិច្ចទៅ ហើយរៀបចំជាស្រុកទេសតាំងក្សត្រឡើងគ្រប់គ្រងប្រទេសៗ

ជនពួកនេះជាមែកធាងរបស់ពួក សេមីទិក (Sémitique) មានខ្សែស្រឡាយចេញមកពីពួកសាលដេ ដែលយើងបានសរសេរពង្សាវតារ ចុះផ្សាយក្នុងកម្ពុជសុរិយា លេខមុននេះរួចមកហើយ ។ ជនពួកនេះជាពួក

អ្នកត្រេចរង្គាត់ មាននាយកម្នាក់ជាមេត្រួតត្រា ហៅថា ប៉ាទ្រីយ៉ាស៍ ជាមេពួក (Patriache) ។ ប៉ាទ្រីយ៉ាស៍ នេះមានអំណាចលើខ្លួនមនុស្សនឹងទ្រព្យសម្បត្តិរបស់មនុស្សដែលនៅក្រោមបង្គាប់, ជាបព្វជិតបង្ហាត់បង្រៀនខាងផ្លូវសាសនា, ជាតុលាការ, ជាមេទ័ព, ជាអ្នកនាំផ្លូវ, ជាអ្នកដំណាងព្រះ នឹងកិច្ចការដទៃទៀតគ្រប់ ៗ ប្រការ ។ ដោយហេតុនេះហើយបានជាប៉ាទ្រី-យ៉ាស៍មានមនុស្សគោរពកោតខ្លាចជាងស្ដេចទៅទៀត ។ មនុស្សពួកនេះនាំគ្នាដើរផ្លូវត្រេចរង្គាត់ទៅតាមសមុទ្រខ្សាច់ សះហារ៉ា កាលបើបានជួបប្រទះនឹងទីដីស្រស់បស់មានដីជាតិល្អត្រង់កន្លែងណា ក៏ឈប់សំចតនៅទីនោះ ដើម្បីឃ្វាលសត្វនឹងស្វែងរកអាហារគោជនសម្រាប់ខ្លួនបរិភោគ ។ លុះទីនោះអស់ដីជាតិហើយ ក៏នាំគ្នាចេញដើរតទៅទៀត ហេតុនេះ បានជាពួកនេះចេញពីមេសូប៉ូតាមី (Mésopotamie) ដែលជាស្រុកកំណើតរបស់ខ្លួនហើយចូលទៅកាន់ប៉ាលេស្ទីន (Palestine) នឹងមានចំនួនជាច្រើនដែលចូលទៅនៅក្នុងប្រទេសអេស៊ីប្ត ប៉ុន្តែទ្រាំការសង្កត់សង្កិនរបស់ពួកអេស៊ីប្តមិនបាន ទើបនាំគ្នាមករួបរួមនៅឯប៉ាលេស្ទីនវិញ ហើយតាំងទីកស្ថានមាំមួននៅទីនោះ ។

ដោយហេតុពួកហេប្រឺនេះ មិនមានស្រុកទេសជាពិតប្រាកដ មិនមានក្សត្រគ្រប់គ្រងផែនដី ។ ពួកដែលធ្វើជាមេជានាយកលើគេនោះមិនមានបុណ្យស័ក្តិប៉ុន្មានទេ បើពួកនេះនាំគ្នាធ្វើបណ្ដាលឡើងនឹងបាន

អ្នកត្រេចរង្គាត់ មាននាយកម្នាក់ជាមេត្រួតត្រា ហៅថា ប៉ាទ្រីយ៉ាស៍ ជាមេពួក (Patriache) ។ ប៉ាទ្រីយ៉ាស៍ នេះមានអំណាចលើខ្លួនមនុស្សនិងទ្រព្យសម្បត្តិរបស់មនុស្សដែលនៅក្រោមបង្គាប់, ជាបព្វជិតបង្ហាត់បង្រៀនខាងផ្លូវសាសនា, ជាតុលាការ, ជាមេទ័ព, ជាអ្នកនាំផ្លូវ, ជាអ្នកជំណាងព្រះ និងកិច្ចការដទៃទៀតគ្រប់ៗប្រការ ។ ដោយហេតុនេះហើយបានជាប៉ាទ្រី-យ៉ាស៍មានមនុស្សគោរពកោតខ្លាចជាងស្ដេចទៅទៀត ។ មនុស្សពួកនេះនាំគ្នាដើរផ្លូវត្រេចរង្គាត់ទៅតាមសមុទ្រខ្សាច់ សះហារ៉ា កាលបើបានជួបប្រទះនឹងទីដីស្រស់បស់មានដីជាតិល្អត្រង់កន្លែងណា ក៏ឈប់សំចតនៅទីនោះ ដើម្បីឃ្វាលសត្វនិងស្វែងរកអាហារភោជនសម្រាប់ខ្លួនបរិភោគ ។ លុះទីនោះអស់ដីជាតិហើយ ក៏នាំគ្នាចេញដើរទៅទៀត ហេតុនេះ បានជាពួកនេះចេញពីមេសូប៉ូតាមី (Mésopotamie) ដែលជាស្រុកកំណើតរបស់ខ្លួនហើយចូលទៅកាន់ប៉ាលេស្ទីន (Palestine) និងមានចំនួនជាច្រើនដែលចូលទៅនៅក្នុងប្រទេសអេស៊ីប ប៉ុន្តែទ្រាំការសង្កត់សង្កិនរបស់ពួកអេស៊ីបមិនបាន ទើបនាំគ្នាមកប្រមូលនៅឯប៉ាលេស្ទីនវិញ ហើយតាំងនិវាសស្ថានមាំមួននៅទីនោះ ។

ដោយហេតុពួកហេប្រឺនេះ មិនមានស្រុកទេសជាពិតប្រាកដ មិនមានក្សត្រគ្រប់គ្រងផែនដី ។ ពួកដែលធ្វើជាមេជានាយកលើគេនោះមិនមានបុណ្យស័ក្តិប៉ុន្មានទេ បើពួកនេះនាំគ្នាធ្វើចលាចលឡើងនឹងបាន

ទទួលសេចក្ដីលំបាកជាច្រើនដែរ ហេតុនេះ ទើបត្រូវតែនាំយកអំណាចខាងលើស្ថានសួគ៌ មកប្រើសម្រាប់ជាគ្រឿងរក្សាសេចក្ដីស្ងប់ ហើយតួសាមីខ្លួនប៉ាទ្រីយ៉ាស៍ជាអ្នកដំណាងព្រះជាម្ចាស់សួគ៌ ។ កាលណាដែលប៉ាទ្រីយ៉ាស៍ធ្វើសុទ្ធតែធ្វើតាមព្រះឱង្ការរបស់ព្រះម្ចាស់សួគ៌ ផ្លូវណាដែលប៉ាទ្រីយ៉ាស៍នាំដើរទៅ ទុកជាផ្លូវដែលត្រូវដើរតាមព្រះឱង្ការរបស់ព្រះ ។ លក្ខណ៍របស់លទ្ធិសាសនាគ្រិស្តក៏កកើតឡើង ដោយមានសេចក្ដីគោរពរាប់អានដល់ព្រះជាម្ចាស់សួគ៌ តាមទំនងដែលពោលមកនេះ ។

ប្រវត្តិសាវតាររបស់ជនពួកនេះ យើងបានដឹងច្បាស់ដោយការសិក្សាប្រវត្តិរបស់ជន ៣-៤ នាក់ ដែលជានាយករបស់ជនពួកនេះ គឺលោកអាប្រ៉ាហាំម (Abraham) មោអ៊ីស (Moïse) ។ យើងអាចស្រង់យកសេចក្ដីអធិប្បាយអំពីគម្ពីរ ប៊ីប៍ (La Bible) មកសំបកចេញហើយរើសយកតែសាច់ប្រវត្តិសាស្ត្រ ដូចមានតទៅនេះ:

អាប្រ៉ាហាំម ជាជាតិសាលដេ កាលកើតសេចក្ដីចង្អៀតតឹងខាងរបរចិញ្ចឹមជីវិត ក៏នាំពួករបស់ខ្លួនចូលទៅតាំងទីកន្លែងនៅស្រុកប៉ាលេស្ទីន តែក្នុងសម័យនោះហៅថាសាណាអង់ (Sanaan) ជាទីដែលមានជនមួយពួកហៅថា សាណាអង់នីយាង នៅទីនោះមុនមកហើយ កាលពួកនេះបានឃើញពួកអាប្រ៉ាហាំមនាំគ្នាចូលមក ទើបតាំងឈ្មោះពួកដែលចូលមកនៅ

ក្រោយនេះថាហេប្រឺ (ប្រែថាពួកខាងនាយ) ។ ទើបពាក្យថា ហេប្រឺ នេះជាឈ្មោះរបស់ជនពួកនេះតាំងអំពីកាលណោះមក ។ ផែនដីដែលពួកអាប្រ៉ាហ័មទៅតាំងនៅថ្មីនេះ មានឈ្មោះម្យ៉ាងទៀតថា "ផែនដីមានខសញ្ញា" ។ ដោយមានរឿងដំណាលថា មុនអាប្រ៉ាហ័មនាំបក្ខពួកចេញមកអំពីមេសូប៉ូតាមីចូលមកនៅក្នុងទីនេះ អាប្រ៉ាហ័មបានទទួលព្រះឱង្ការរបស់ព្រះជាម្ចាស់ ថានឹងប្រទានទឹកន្លែងដ៏មានដីជាតិល្អដល់ជនពួកនេះ ។

កាលអាប្រ៉ាហ័មអនិច្ចកម្មទៅ ទើបអ៊ីសាអ័ក (Isaac) ជាបុត្រអាប្រ៉ាហ័មក៏បានទទួលដំណែងជានាយក (ប៉ាទ្រីយ៉ាស៍) ជំនួស ។ អ៊ីសាអ័កមានកូនប្រុស ២ នាក់ ឈ្មោះអេសាវ (Esau) ១ ឈ្មោះសាកុប ១ ។ ឯភរិយារបស់អ៊ីសាអ័ក ស្រឡាញ់កូនទី ២ ច្រើនជាងកូនបង ទើបធ្វើឧបាយបន្លំឲ្យអ៊ីសាអ័ក តាំងសាកុបឲ្យធ្វើជាប៉ាទ្រីយ៉ាស៍ជំនួសខ្លួនកាលដល់ខ្លួនស្លាប់ទៅ ។ រឿងនេះជាហេតុឲ្យកូនច្បងមានចិត្តក្រោធខឹងប៉ងប្រទូសរ៉ាយទាល់តែសាកុបនោះមិនបានតោងរត់ចេញពីពួកខ្លួនទៅ ហើយត្រឡប់ចូលទៅក្នុងផែនដីរបស់សាលដេវិញ ហើយបានភរិយានៅទីនោះមានកូនដល់ទៅ ១២ នាក់ ។ លុះត្រឡប់មកស្រុកប៉ាលេស្ទីនវិញតាំងខ្លួនជាអ្នកគោរពខ្ជាប់ខ្ជួនដល់ព្រះជាម្ចាស់សួគ៌ ធ្វើពិធីតាមផ្លូវសាសនា ហើយហៅឈ្មោះខ្លួនក្នុងវេលាធ្វើពិធីថា "អ៊ីស្រាអិល" (Israël) ។ លុះកាលតមកសាកុបបានធ្វើជាធំក្នុងពួកហេប្រឺឡើងហើយ ក៏បែកបែងពួកមនុស្ស

ក្រោយនេះថាហេប្រឺ (ប្រែថាពួកខាងនាយ) ។ ទើបពាក្យថា ហេប្រឺ នេះជាឈ្មោះរបស់ជនពួកនេះតាំងអំពីកាលណោះមក ។ ផែនដីដែលពួកអាប្រាហាំមទៅតាំងនៅថ្មីនេះ មានឈ្មោះម្យ៉ាងទៀតថា "ផែនដីមានខសញ្ញា" ។ ដោយមានរឿងដំណាលថា មុនអាប្រាហាំមនាំបក្ខពួកចេញមកអំពីមេសូប៉ូតាមីចូលមកនៅក្នុងទីនេះ អាប្រាហាំមបានទទួលព្រះឧង្ការរបស់ព្រះជាម្ចាស់ ថានឹងប្រទានទឹកន្លែងដ៏មានជីជាតិល្អដល់ជនពួកនេះ ។

កាលអាប្រាហាំមអនិច្ចកម្មទៅ ទើបអ៊ីសាអ៉ក (Isaac) ជាបុត្រអាប្រាហាំមក៏បានទទួលតំណែងជានាយក (ប៉ាទ្រីយ៉ាស៍) ជំនួស ។ អ៊ីសាអ៉កមានកូនប្រុស ២ នាក់ ឈ្មោះអេសាវ (Esau) ១ ឈ្មោះសាកុប ១ ។ ឯភរិយារបស់អ៊ីសាអ៉ក ស្រឡាញ់កូនទី ២ ច្រើនជាងកូនបង ទើបធ្វើឧបាយបន្លំឲ្យអ៊ីសាអ៉ក តាំងសាកុបឲ្យធ្វើជាប៉ាទ្រីយ៉ាស៍ជំនួសខ្លួនកាលដល់ខ្លួនស្លាប់ទៅ ។ រឿងនេះជាហេតុឲ្យកូនច្បងមានចិត្តក្រោធខឹងប៉ងប្រទូសរ៉ាយទាល់តែសាកុបនៅមិនបានតោងរត់ចេញពីពួកខ្លួនទៅ ហើយត្រឡប់ចូលទៅក្នុងផែនដីរបស់សាលដេវិញ ហើយបានភរិយានៅទីនោះមានកូនដល់ទៅ ១២ នាក់ ។ លុះត្រឡប់មកស្រុកបាលេស្ទីនវិញតាំងខ្លួនជាអ្នកគោរពខ្ជាប់ខ្ជួនដល់ព្រះជាម្ចាស់ស្លូត ធ្វើពិធីតាមផ្លូវសាសនា ហើយហៅឈ្មោះខ្លួនក្នុងវេលាធ្វើពិធីថា "អ៊ីស្រាអ៊ែល" (Israël) ។ លុះកាលតមកសាកុបបានធ្វើជាធំក្នុងពួកហេប្រឺឡើងហើយ ក៏ចែកបែងពួកមនុស្ស

ជា ១២ ពួក ហើយចាត់តាំងកូនរបស់ខ្លួនជាមេពួកមេក្រុមម្នាក់ ១ ពួក ៗ ដោយហេតុនេះពួកហេប្រឺទើបមានឈ្មោះម្យ៉ាងទៀតថា អ៊ីស្រាអេលីត (Israélites) ប្រែថា ជាកូនរបស់ អ៊ីស្រាអិល ។

ក្នុងពួកកូនទាំង ១២ នាក់របស់សាកុបនោះ មានកូនម្នាក់ឈ្មោះ សូសេហ្វ (Joseph) ជាកូនដែលម្ដាយឪពុកស្រឡាញ់ច្រើនជាងកូនឯទៀត ៗ ទើបជាហេតុធ្វើឲ្យកូនក្រៅពីនេះ មានចិត្តច្រណែនឈ្នានីស ហើយគប់គិតគ្នាលបលួចសូសេហ្វទៅលក់ឲ្យអ្នកដំនួញជាតិអេស៊ីប្ទម្នាក់ ៗ សូសេហ្វធ្លាក់ខ្លួនទៅនៅជាខ្ញុំក្នុងផសំណាក់ប្រទេសអេស៊ីប្ទ ហើយបាន ធ្វើជាកដបំរើរបស់ក្សត្រអេស៊ីប្ទ ខណៈនោះប្រាកដថា សូសេហ្វជា អ្នកស្ទាត់ជំនាញខាងការទំនាយយល់សប្តិ ៗ ថ្ងៃមួយ បានធ្វើទំនាយព្រះ សុបិនរបស់ក្សត្រអេស៊ីប្ទបានត្រឹមត្រូវ ទឹងរកឲបាយការពារប្រទេសអេ-ស៊ីប្ទឲ្យផុតពីទុព្ភិក្ខភ័យបាន ទើបក្សត្រប្រទេសអេស៊ីប្ទ ទ្រង់ប្រោសតាំង ឲ្យធ្វើជាអគ្គមហាសនាបតី ហើយបាននាំបក្ខពួកៈទៅនៅប្រទេសអេស៊ីប្ទ ជាចំនួនច្រើន ។

ពួកហេប្រឺ ជាមនុស្សខ្នះខ្នែងខ្លាំងពូកែក្នុងការតស៊ូនឹងទ្រុកដីអាកាស ហើយធ្វើការបានច្រើនផង ទើបជាហេតុធ្វើឲ្យក្សត្រប្រទេសអេស៊ីប្ទជាន់ ក្រោយ ៗ មកនឹកខ្លាចក្រែងមានភ័យកើតឡើងដល់ម្ចាស់ស្រុក ទើបចាត់

ពួកនេះឲ្យទៅនៅទីមួយដោយឡែក មិនឲ្យលាយឡំនឹងជនជាតិអេស៊ីប្ត
ហើយគេណាឲ្យធ្វើការធ្ងន់ៗ សង្កត់សង្កិនឲ្យធ្វើជាខ្ញុំ ទាំងចាប់ខ្លួនទៅលក់
ហើយធ្វើបាបឥតត្រាប្រណីៗ ឯពីរ៉ាមិត ដែលជាថាវរវត្ថុយ៉ាងឧត្តមឯក
របស់អេស៊ីប្តមានទៅរហូតដល់សព្វថ្ងៃនេះ ក៏បានសំរេចឡើងបាន ដោយ
កំឡាំងរបស់ពួកហេព្រឺជាច្រើនដែរ ។ សូម្បីបានសេចក្តីលំបាកវេទនា
យ៉ាងណាក៏ដោយ ពួកហេព្រឺក៏នៅតែបែកមែកធាង មានកូនចៅ
សាយភាយកាន់តែមានចំនួនច្រើនឡើងទៀត ទាល់តែក្សត្រផែនដីអេស៊ីប្ត
ចេញព្រះរាជប្រកាសឲ្យចាប់យកក្មេងៗដែលកើតថ្មីយកទៅសម្លាប់អស់ជា
ច្រើន ៗ មានក្មេងម្នាក់ដែលរស់រួចពីស្លាប់ ដោយម្តាយយកទៅដាក់ក្នុង
ជាលបណ្តែតទឹកទៅ ក្មេងនោះអណ្តែតទៅដល់ទីកំពង់ដែលរាជធីតារបស់
ក្សត្រប្រទេសអេស៊ីប្តតែងចុះស្រង់ហើយជួបប្រទះឃើញក្មេងនោះ ទ្រង់
យល់ថាក្មេងនេះគួរអាណិតអាសូរណាស់ ហើយទ្រង់រើសយកទៅចិញ្ចឹម
តាំងឈ្មោះថា មោអ៊ិស(Moïse: ជួយរួចពីទឹក)ៗ លុះគាត់ធំចំរើនឡើងក៏បាន
ធ្វើជាអធិបតីនៃពួកហេព្រឺ តែឥឡូវនេះ គេហៅថា អ៊ីស្រាអែលិត ៗ មោ-
អ៊ិសបានឃើញសេចក្តីលំបាកវេទនារបស់ពួកខ្លួនកាន់តែច្រើនឡើងៗទើប
គិតគូរនាំបក្ខពួករបស់ខ្លួនចេញពីប្រទេសអេស៊ីប្ត ត្រឡប់ទៅនៅក្នុងប៉ា-
លេស្ទីនវិញ ។ ដំបូង ក្សត្រប្រទេសអេស៊ីប្តមិនទ្រង់អនុញ្ញាត ព្រោះ

ពួកនេះឲ្យទៅនៅទីមួយដោយឡែក មិនឲ្យលាយឡំនឹងជនជាតិអេស៊ីប្ទ ហើយគេណែឲ្យធ្វើការធ្ងន់ៗ សង្កត់សង្កិនឲ្យធ្វើជាខ្ញុំ ទឹងចាប់ខ្លួនទៅលក់ ហើយធ្វើបាបឥតត្រាប្រណី ៗ ឯពីកំមិត ដែលជាថាវរត្ថយ៉ាងឧត្តមឯក របស់អេស៊ីប្ទមាននៅរហូតដល់សព្វថ្ងៃនេះ ក៏បានសំរេចឡើងបាន ដោយកំឡាំងរបស់ពួកហេប្រឺជាច្រើនដែរ ។ សូម្បីបានសេចក្ដីលំបាកវេទនាយ៉ាងណាក៏ដោយ ពួកហេប្រឺក៏នៅតែបែកមែកធាង មានកូនចៅសាយភាយកាន់តែមានចំនួនច្រើនឡើងទៀត ទាល់តែក្សត្រផែនដីអេស៊ីប្ទចេញព្រះរាជប្រកាសឲ្យចាប់យកក្មេងៗដែលកើតថ្មីយកទៅសម្លាប់អស់ជាច្រើន ៗ មានក្មេងម្នាក់ដែលរស់រួចពីស្លាប់ ដោយម្ដាយយកទៅដាក់ក្នុងជាលបណ្ដែតទឹកទៅ ក្មេងនោះអណ្ដែតទៅដល់ទីកំពង់ដែលរាជធីតារបស់ក្សត្រប្រទេសអេស៊ីប្ទតែងចុះស្រង់ហើយជួបប្រទះឃើញក្មេងនោះ ទ្រង់យល់ថាក្មេងនេះគួរអាណិតអាសូរណាស់ ហើយទ្រង់រើសយកទៅចិញ្ចឹមតាំងឈ្មោះថា មោអ៊ិស (Moïse: ជួយរួចពីទឹក)ៗ លុះធាត់ធំចំរើនឡើងក៏បានធ្វើជាអធិបតីនៃពួកហេប្រឺ តែឥឡូវនេះ គេហៅថា អ៊ីស្រាអែលីត ៗ មោអ៊ិសបានឃើញសេចក្ដីលំបាកវេទនារបស់ពួកខ្លួនកាន់តែច្រើនឡើងៗទើបគិតគូរនាំបក្ខពួករបស់ខ្លួនចេញពីប្រទេសអេស៊ីប្ទ ត្រឡប់ទៅនៅក្នុងប៉ាលេស្ទីនវិញ ។ ដំបូង ក្សត្រប្រទេសអេស៊ីប្ទមិនទ្រង់អនុញ្ញាត ព្រោះ

នៅត្រូវការពួកអ៊ីស្រាអែលទុកប្រើការក្នុងស្រុកតទៅទៀត តែជួនជាក្នុងឆ្នាំនោះកើតទឹកធំ ស្រុកលិចទឹកនឹងមានរាកត្ដូងកើតឡើងយ៉ាងធំសំបើមក្នុងប្រទេសអេស៊ីប្ដ៍ ជាហេតុធ្វើឲ្យព្រះចៅផែនដីប្រទេសអេស៊ីប្ដ៍ទ្រង់ទើករង្កៀសថា ក្រែងតែពួកនេះនាំសេចក្ដីវិនាសហិនហោចមកកាន់ប្រទេសរបស់ទ្រង់ ទើបទ្រង់អនុញ្ញាតឲ្យពួកអ៊ីស្រាអែលលើកចេញពីស្រុកទៅបាន តែតមកក្រោយនោះបន្តិច ទ្រង់ទើកសង្ស័យក្រែងពួកនេះទៅបបួលដឹកនាំប្រទេសដទៃ ៗ មានស៊ីរីជាដើមមកច្បាំងនឹងប្រទេសអេស៊ីប្ដ៍ ៗ ទើបទ្រង់បញ្ជូនកងទាហានឲ្យដេញទៅតាមក្រោយ ដើម្បីឲ្យចាប់ពួកអ៊ីស្រា-អែលប្រហារជីវិតឲ្យអស់ទៅ តែកងទាហានអេស៊ីប្ដ៍ទៅតាមមិនទាន់ ព្រោះកាលកងទាហានទៅដល់មាត់សមុទ្រក្រហមនោះ ពួកអ៊ីស្រាអែលឆ្លងសមុទ្រក្រហមផុតអស់ទៅហើយ នាំគ្នាដើរសោត់ក្រាត់ត្រេបរង្គត់នៅក្នុងសមុទ្រខ្សាច់ស៊ីណាអ៊ី (Sinaï) ទីនេះព្រៃភ្នំក្រមថ្ម នៅតំបន់នោះជាវេលាយូរ បានទទួលសេចក្ដីលំបាកវេទនាជាពន្លឹក ស្ទើរតែពួកនេះកើតគំនិតគិតឃើញថាព្រះរបស់ខ្លួនមិនខ្លាំងពូកែពិតមែនទេ តែមោអ៊ីសបានពោលលួងពួកនេះឲ្យផ្លាស់គំនិតត្រឡប់មកជឿព្រះវិញបាន ដោយពោលអាងថា ខ្លួនបានទទួលបញ្ញត្តិ ១០ ប្រការមកអំពីព្រះជាម្ចាស់សួគ៌ ហើយអំណើះតមកទើបនាំគ្នាចូលទៅនៅក្នុងខេត្រប៉ាលេស្ទីន ដែលជាផែនដី

មានខសញ្ញា (La terre Promise) ជាទីដែលអាប្រាហាំមបាននាំពួកទៅតាំងនៅកាលសម័យជាន់ដើមនោះ ហើយពួកហេប្រឺ ឬអ៊ីស្រាអេលក៏តាំងឡាក់ឋាននៅក្នុងតំបន់ប៉ាលេស្ទីនដោយខ្ជាប់ខ្ជួនតរៀងមកដោយប្រការដូច្នេះ ។

ឯបញ្ញត្តិ ១០ ប្រការនោះមានសេចក្ដីដូច្នេះ:

១) កុំគោរពរាប់អានព្រះដទៃទៀត

២) កុំគោរពបូជារូបគោរព

៣) កុំពោលចេញព្រះនាមព្រះយេហូវ៉ា (Jéhovah) លេងទទេ ៗ

៤) ចូរនាំគ្នាធ្វើការងារឲ្យបានសម្រេចឲ្យហើយក្នុងរវាង ៦ ថ្ងៃ តែថ្ងៃទី ៧ គឺថ្ងៃអាទិត្យ នោះកុំធ្វើការអ្វី ៗ ឡើយ ។

៥) ចូរគោរពរាប់អានមាតាបិតារបស់ខ្លួន

៦) កុំសម្លាប់មនុស្ស

៧) កុំកន្លងប្រវេណីប្រុសស្រី ( ទំនងសហាយគ្នា )

៨) កុំលួចទ្រព្យគេ

៩) កុំធ្វើជាសាក្សីពោលបង្ខុសគេ

១០) កុំលោភយកផ្ទះរបស់អ្នកជិតខាង កុំលោភលើកិរិយារបស់អ្នកដទៃ ឬខ្ញុំប្រុសស្រីគោលារបស់គេ ឬរបស់ឯណាទីមួយដែលជារបស់ញាតិមិត្តជិតខាងខ្លួន ។

មានខសញ្ញា (La terre Promise) ជាទីដែលអាប្រាហាំមបាននាំពួកទៅតាំងនៅកាលសម័យជាន់ដើមនោះ ហើយពួកហេប្រឺ ឬអ៊ីស្រាអែលក៏តាំងឡាក់ឋាននៅក្នុងតំបន់ប៉ាលេស្ទីនដោយខ្ជាប់ខ្ជួនតរៀងមកដោយប្រការដូច្នេះ ។

ឯបញ្ញត្តិ ១០ ប្រការនោះមានសេចក្ដីដូច្នេះ:

១) កុំគោរពរាប់អានព្រះដទៃទៀត

២) កុំគោរពបូជារូបគោរព

៣) កុំពោលចេញព្រះនាមព្រះយេហូវ៉ា (Jéhovah) លេងទទេ ។

៤) ចូរនាំគ្នាធ្វើការងារឲ្យបានសម្រេចឲ្យហើយក្នុងរវាង ៦ ថ្ងៃ តែថ្ងៃទី ៧ គឺថ្ងៃអាទិត្យ នោះកុំធ្វើការអ្វីៗឡើយ ។

៥) ចូរគោរពរាប់អានមាតាបិតារបស់ខ្លួន

៦) កុំសម្លាប់មនុស្ស

៧) កុំកន្លងប្រវេណីប្រុសស្រី (ទំនងសហាយគ្នា)

៨) កុំលួចទ្រព្យគេ

៩) កុំធ្វើជាសាក្សីពោលបង្ខុសគេ

១០) កុំលោភយកផ្ទះរបស់អ្នកជិតខាង កុំលោភលើកិរិយារបស់អ្នកដទៃ ឬខ្ញុំប្រុសស្រីគោលារបស់គេ ឬរបស់ឯណាទីមួយដែលជារបស់ញាតិមិត្តជិតខាងខ្លួន ។



២២- អំពីទ្រង់ទទួលបាច់ស្មៅរបស់សុត្ថិកព្រាហ្មណ៍

# បញ្ជីរូបនៃសារមន្ទីរនៅស្រុកកល់គុត្តា
# និយាយពីរចនាក្រិក-ពុទ្ធសាសនា

(Gréco-Bouddhique) នៅស្រុកគន្ធារ

ក្នុងសៀវភៅតូចនេះ គេតែងជាភាសាអង់គ្លេស ព្រះរាជបណ្ណាល័យទើបនឹងបានទទួលមក ជាសៀវភៅមានប្រយោជន៍ធំដល់អ្នកកាន់ព្រះពុទ្ធសាសនានៅស្រុកខ្មែរ ព្រោះសៀវភៅនេះមានសេចក្ដីពន្យល់អំពីគ្រឿងបំឡាក់រចនាបែបពុទ្ធសាសនា នៅប្រទេសឥណ្ឌាខាងជើង មានទាំងបោះពុម្ពរូបថតជាចំនួនច្រើនផង ។ ក្នុងអារម្ភកថាសៀវភៅនោះ លោកអ្នកតែងសៀវភៅនិយាយពន្យល់យើង អំពីបែបរចនាដែលហៅថា ក្រិក-ពុទ្ធសាសនា (Gréco-Bouddhique) តាំងពីពុទ្ធសាសនាកន្លងទៅ ៧៥០ នោះ មានទំនងដូចជាស្រុកគន្ធារៈជាន់ដើមបំផុតនៅស្រុកឥណ្ឌាខាងជើង មានព្រំប្រទល់នឹងស្រុកបុរាណមួយដែលហៅថា តក្កសិលា ។ ការរចនាឆ្លាក់រូបដោយដីពណ៌ស្មើរខៀវខ្មៅ ដែលគេរកឃើញនៅលើក្នុងនៃតំបន់អស់នោះ បែបរចនាទំនងនេះយើងមានគំរូនៅសារមន្ទីរនៃព្រះរាជបណ្ណាល័យដែរ ។

ខែត្រគន្ធារៈនេះមានឡាក់ហានតាមប្រវត្តិសាស្ត្រ ចង្អុលឲ្យឃើញថា ត្រង់ផ្លូវបែកជា ៤ នោះជាកន្លែងមានសេចក្ដីចំរើន (អារ្យធម៌) បែកចេញជា ៣ ផ្នែក គឺ ១ មកពីប្រទេសឥណ្ឌា ២ មកពីក្រិក ៣ មកពីអ៊ីរ៉ាន (ប្រទេស

ពែរ្ស៍) ដែលបានឲ្យកំណើតដល់បែបរចនានៃស្រុកគន្ធារៈ តែអាស្រ័យធម៌នេះលាយច្របល់គ្នា ដោយហេតុចេញមកពីប្រទេសផ្សេងៗគ្នា ។

ឯគ្រឿងប្រដាប់តាក់តែងជាន់ដើម វិធីធ្វើម្រង់ទ្រង់មុខ និងគ្រឿងសម្លៀកបំពាក់ផ្សេងៗ សុទ្ធតែជាបែបក្រិក តែក្នុងខណៈនោះ គោលធំៗនិងរូបដំណាងផ្សេងៗនៅជារបស់ឥណ្ឌា ។ ចំណែកឯរូបដែលមើលឃើញជិតឆ្ងាយនិងបែបក្បាច់រចនាសំខាន់ៗ មានកំណើតមកពីក្រិកដែរ ។ តែឯរូបជាដំណាងព្រះពុទ្ធ គេកសាងជាសាលាចម្លាក់មួយនៅស្រុកគន្ធារៈ ព្រោះកាលជាន់នោះ នៅប្រទេសឥណ្ឌាមិនមានរូបដំណាងព្រះពុទ្ធតាមបែបភាពជាមនុស្សសោះឡើយ; រូបដែលធ្វើឡើងថ្មីមួយបែបទៀត ជាបែបរចនារបស់គន្ធារៈនោះ គឺជារូបដំណាងព្រះពោធិសត្វ ដែលមានច្រើនទៅជាសក្ដិព្រះពុទ្ធសាសនាបែបមហាយាន ។ ក្នុងសម័យនោះ នៅប្រទេសឥណ្ឌាមានបង្កើតរចនាមួយបែបទៀតជាបែបគន្ធារៈដែរ គឺធ្វើឲ្យមានរស្មីនៅលើព្រះកេសព្រះពុទ្ធរូប តែព្រះពោធិសត្វគេមិនធ្វើទេ ។

ឯគោលសំខាន់ៗ តាមក្បាច់ចម្លាក់អស់នោះគឺ:

១) ជាតកទាំងឡាយដែលយើងធ្លាប់ដឹងរឿងរ៉ាវ គឺស្យាមជាតក ឆទ្ទន្តជាតក វេស្សន្តរជាតក សិពីជាតក ឬស្សសិង្គជាតក និងទីបង្ករជាតក រួមទាំងចន្ទកិន្នរជាតកផង ។

ប៉ែរ្ស៍) ដែលបានឲ្យកំណើតដល់បែបរចនានៃស្រុកគន្ធារៈ តែអារ្យធម៌នេះ លាយច្របល់គ្នា ដោយហេតុចេញមកពីប្រទេសផ្សេងៗគ្នា ។

ឯគ្រឿងប្រដាប់តាក់តែងជាន់ដើម វិធីធ្វើទម្រង់ទ្រង់មុខ និងគ្រឿងសម្លៀកបំពាក់ផ្សេងៗ សុទ្ធតែជាបែបក្រិក តែក្នុងខណៈនោះ គោលធំៗ និងរូបដំណាងផ្សេងៗនៅជារបស់ឥណ្ឌា ។ ចំណែកឯរូបដែលមើលឃើញ ជិតឆ្ងាយនិងបែបក្បាច់រចនាសំខាន់ៗ មានកំណើតមកពីក្រិកដែរ ។ តែឯរូបជាដំណាងព្រះពុទ្ធ គេកសាងជាសាលាចម្លាក់មួយនៅស្រុកគន្ធារៈ ព្រោះកាលជាន់នោះ នៅប្រទេសឥណ្ឌាមិនមានរូបដំណាងព្រះពុទ្ធតាមបែបភាពជាមនុស្សសោះឡើយ; រូបដែលធ្វើឡើងថ្មីមួយបែបទៀត ជាបែបរចនារបស់គន្ធារៈនោះ គឺជារូបដំណាងព្រះពោធិសត្វ ដែលមានច្រើនជេរជាសក្នុងព្រះពុទ្ធសាសនាបែបមហាយាន ។ ក្នុងសម័យនោះ នៅប្រទេសឥណ្ឌាមានបង្កើតរចនាមួយបែបទៀតជាបែបគន្ធារៈដែរ គឺធ្វើឲ្យមានរស្មីនៅលើព្រះកេសព្រះពុទ្ធរូប តែព្រះពោធិសត្វគេមិនធ្វើទេ ។

ឯគោលសំខាន់ៗ តាមក្បាច់ចម្លាក់អស់នោះគឺ:

១) ជាតកទាំងឡាយដែលយើងធ្លាប់ដឹងរឿងរ៉ាវ គឺស្យាមជាតក ឆទ្ទន្តជាតក វេស្សន្តរជាតក ស៊ីពីជាតក ឫស្សស្រិង្គជាតក និងទីបង្ករជា-តក រួមទាំងចន្ទគិន្នរជាតកផង ។

២) អំពីដំណើរពុទ្ធប្បវត្តិដែលមានជារូបចម្លាក់ផ្សេងៗ នោះគឺ:

- ព្រះនាងមហាមាយាទ្រង់សុបិននិមិត្ត និងថ្លែងពីសុបិននិមិត្តនោះ ។
- ព្រះនាងមហាមាយាស្ដេចយាងទៅប្រពាតសួនលុម្ពិនី ។
- ព្រះពោធិសត្វប្រសូត ។
- នាយឆន្ន: និងសេះកណ្ឋក: ក៏កើតដែរ ។
- ព្រះពោធិសត្វទ្រង់ឈាន ៧ ជំហាន
- ទ្រង់ស្រង់ទឹកជាដំបូង-ព្រះឥន្ទ្រនិងព្រះព្រហ្មទ្រង់ចាក់ទឹកស្រោចព្រះសិរព្រះអនាគតពុទ្ធ ។
- ព្រះនាងមហាមាយានិងព្រះអនាគតពុទ្ធស្ដេចត្រឡប់មកក្រុងកបិលពស្តុវិញ ។
- អសិតតាបសធ្វើទំនាយទាយព្រះពោធិសត្វ ។
- ព្រះពោធិសត្វសិក្សាក្នុងសាលារៀន យើងឃើញព្រះអង្គកំពុងសរសេរអក្សរលើសន្លឹកក្ដារឈ្ពន (លីបីផលក) ។
- ព្រះពោធិសត្វទ្រង់អភិសេក ។
- មុនស្ដេចចេញមហាភិនេស្ក្រមណ៍ នៅក្នុងពំនួកស្រីៗកំពុងដេកលក់ស៊ប់ ។
- មហាភិនេស្ក្រមណ៍ ទ្រង់លះបង់មិនអាល័យ ។
- ទ្រង់ជួបនឹងព្រះបាទពិម្ពិសារ ។

— ទ្រង់ធ្វើទុក្ករកិរិយា ។

— ស្ដេចនាគកាលិកមកធ្វើសក្ការបូជាព្រះពុទ្ធជាម្ចាស់ ព្រមទាំងភរិយា ។

— ទ្រង់គង់លើរតនបល្ល័ង្ក ។

— ទ្រង់ផ្ចាញ់ក្រុងមារ ។

— អ្នកជំនួញពីរនាក់ឈ្មោះតបុស្សៈ ១ ភល្លិកៈ ១ មកធ្វើសក្ការបូជាព្រះអង្គ គឺនៅមានរឿងរ៉ាវ ១៨ ទៀត រហូតដល់ចូលនិព្វានហើយ មានរូបមឈូសព្រះសព ហើយនិងធ្វើពិធីបូជាព្រះភ្លើង ក្នុងទីបំផុតចែកសារីរិកធាតុ និងរូបស្តូបជាទីដំកល់ព្រះសារីរិកធាតុ និងរូបដំណាងព្រះរតនត្រៃ ។

៣) ក្រៅពីនេះនៅមានរូបផ្សេងៗ ដែលមិនសូវសំខាន់ប៉ុន្មានទេ ឯរូបដែលបានបោះពុម្ពនៅខាងចុងសៀវភៅនេះជាគំនិតបំពេញបែបបទនា នឹងសេចក្ដីសំខាន់ៗ ដែលបានថ្លែងមកនេះ ។

— ទ្រង់ធ្វើទុក្ករកិរិយា ។

— ស្តេចនាគកាលិកមកធ្វើសក្ការបូជាព្រះពុទ្ធជាម្ចាស់ ព្រមទាំងភរិយា ។

— ទ្រង់គង់លើរតនបល្ល័ង្ក ។

— ទ្រង់ផ្ចាញ់ក្រុងមារ ។

— អ្នកជំនួញពីរនាក់ឈ្មោះតបុស្ស: ១ ភល្លិក: ១ មកធ្វើសក្ការបូជាព្រះអង្គ តទៅនៅមានរឿងរ៉ាវ ១៨ ទៀត រហូតដល់ចូលនិព្វានហើយ មានរូបមឈូសព្រះសព ហើយនឹងធ្វើពិធីបូជាព្រះភ្លើង ក្នុងទីបំផុតចែកសារីរិកធាតុ នឹងរូបស្តូបជាទីដំកល់ព្រះសារីរិកធាតុ នឹងរូបដំណាងព្រះរតនត្រៃ ។

៣) ក្រៅពីនេះនៅមានរូបផ្សេងៗ ដែលមិនសូវសំខាន់ប៉ុន្មានទេ ឯរូបដែលបានបោះពុម្ពនៅខាងចុងសៀវភៅនេះជាគំនិតបំពេញបែបបទនា នឹងសេចក្តីសំខាន់ៗ ដែលបានថ្លែងមកនេះ ។

# និយាយពីប្រទេសភូមា
# ក្នុងសម័យអង់គ្លេសចាត់ការគ្រប់គ្រង

មានទស្សនាវដ្ដីអង់គ្លេសមួយ ហៅថា "Géographical magazine" ចុះថ្ងៃផ្សាយក្នុងខែឧកតូប្រឆ្នាំ ១៩៣៩ មានរឿងមួយនិយាយពីប្រទេសភូមា ដែលចៅក្រមជាតិអង់គ្លេសម្នាក់ឈ្មោះលោក Maurice collis បានរៀបរៀងឡើង ។ លោកនេះបាននៅក្នុងស្រុកភូមាជាវេលាយូរ បានតែងរឿងពីស្រុកនេះ ដូចមានខាងក្រោមនេះ

កាលពីសតវត្សរ៍ទី ១៩ នៃពុទ្ធសករាជ ប្រទេសភូមាជាប្រទេសដែលមានជនជាតិផ្សេងៗជាច្រើនជាតិ ដូចជាភូមា ការេន តាឡេង ទីន ឆាន ជាដើម ដែលមានចំនួនច្រើន ។ ពួកជនជាតិភូមានេះធ្លាប់លើកទ័ពចូលលុកលុយដណ្ដើមយកក្រុងអយុធ្យារបស់សៀមបានហើយ ទើបលើកទ័ពចូលទៅវាយស្រុកក្លិង្គទៀត ។ ក្នុងខណៈនោះរាជការប្រទេសអង់គ្លេសចង់សុំធ្វើសន្ធិភាពនឹងប្រទេសភូមាដែរ តែយល់ថាការធ្វើបែបនេះមិនមានប្រយោជន៍ទេ ទើបរាជការអង់គ្លេសវាយដណ្ដើមយកខែត្រទាំងឡាយតាមមាត់សមុទ្រប្រទេសភូមា ក្នុង ព. ស. ២៣៦៨ ។

ក្នុងពេល ២៧ ឆ្នាំតមក ទើបពួកអង់គ្លេសធ្វើចម្បាំងនឹងរាជសំណាក់ក្រុងអង្វៈ លុកលុយយកបានខែត្រខ្លះដែលមានផែនដីដីជាតិល្អអំពីប្រទេសភូមាទៅ ។

ក្នុងរវាង ព.ស. ២៤២៨ ទើបមានពួកបារាំងសែសមកតាំងទីកន្លែង នៅប្រទេសឥណ្ឌូស៊ីន ហើយបានបញ្ជូនពួកទូត ១ ក្រុមទៅក្រុងមណ្ឌលេ ដើម្បីធ្វើសន្យាខាងផ្លូវជំនួញនឹងព្រះចៅធីបូ ។ ឯពួកអង់គ្លេសមាន សេចក្ដីស្ញើបក្រែងអានុភាពរបស់បារាំងសែសកាលដាលចូលមកដល់មហាអាណាចក្រឥណ្ឌា ទើបអ្នកសម្រេចរាជការប្រទេសឥណ្ឌាបង្ខំស្តេចក្រុងមណ្ឌលេឲ្យទ្រង់ទទួលអ្នកដំណាងរាជការអង់គ្លេសម្នាក់ ឲ្យដូចជាទ្រង់ទទួលអ្នកដំណាងបារាំងសែសដែរ ។ ឯស្តេចភូមាមិនទ្រង់យល់ព្រម ទ្រង់មានព្រះឱង្ការថា ប្រទេសទ្រង់ជាប្រទេសឯករាជ្យ ត្រូវតែទ្រង់មានអំណាចធ្វើការអ្វីៗ បានតាមសព្វព្រះទ័យរបស់ទ្រង់ ។ ក្នុងខណៈនោះឯង មន្ត្រីធំជាអ្នកសម្រេចរាជការប្រទេសឥណ្ឌា បានប្រកាសសង្គ្រាមនឹងប្រទេសភូមា ក្នុងរវាង ១៥ ថ្ងៃ មណ្ឌលេភូមាក៏នៅក្នុងកណ្ដាប់ដៃអង់គ្លេស ព្រះរាជវាំងក៏ត្រូវគេរឹបជាន់ មានព្រះរាជទ្រព្យខ្លះក្នុងឃ្លាំងហ្លួង ដល់មកឥឡូវនេះគេយកទៅដាក់ទុកក្នុងពិពិធភណ្ឌស្ថានធំនៅក្រុងឡុងដ៍អង់គ្លេសក៏មាន សល់អំពីនេះ គេយកទៅលក់ឡាយឡុង គិតជាប្រាក់ប្រហែលជា ១.០៧២.៤០០ រៀល ឯព្រះរាជាភូមានឹងអគ្គមហេសីនឹងព្រះវរជននីមាតាត្រូវនិរទេសទៅនៅស្រុកឥណ្ឌា ។

ក្នុងរវាង ព.ស. ២៤២៨ ទើបមានពួកបារាំងសែសមកតាំងទីកន្លែង នៅប្រទេសឥណ្ឌូស៊ីន ហើយបានបញ្ជូនពួកទូត ១ ក្រុមទៅក្រុងមណ្ឌលេ ដើម្បីធ្វើខសន្យាខាងផ្លូវជំនួញនឹងព្រះចៅធីបូ ។ ឯពួកអង់គ្លេសមាន សេចក្ដីស្រើបក្រែងអានុភាពរបស់បារាំងសែសរាលដាលចូលមកដល់មហា អាណាចក្រឥណ្ឌា ទើបអ្នកសម្រេចរាជការប្រទេសឥណ្ឌាបង្ខំស្ដេច ក្រុងមណ្ឌលេឲ្យទ្រង់ទទួលអ្នកដំណាងរាជការអង់គ្លេសម្នាក់ ឲ្យដូចជាទ្រង់ ទទួលអ្នកដំណាងបារាំងសែសដែរ ។ ឯស្ដេចភូមាមិនទ្រង់យល់ព្រម ទ្រង់ មានព្រះឱង្ការថា ប្រទេសទ្រង់ជាប្រទេសឯករាជ្យ ត្រូវតែទ្រង់មាន អំណាចធ្វើការអ្វីៗ បានតាមសព្វព្រះទ័យរបស់ទ្រង់ ។ ក្នុងខណៈនោះឯង មន្ត្រីធំជាអ្នកសម្រេចរាជការប្រទេសឥណ្ឌា បានប្រកាសសង្គ្រាមនឹង ប្រទេសភូមា ក្នុងរវាង ១៥ ថ្ងៃ មណ្ឌលេភូមាក៏នៅក្នុងកណ្ដាប់ដៃអង់គ្លេស ព្រះរាជវាំងក៏ត្រូវគេរឹបជាន់ មានព្រះរាជទ្រព្យខ្លះក្នុងឃ្លាំងហ្លួង ដល់មក ឥឡូវនេះគេយកទៅដំកល់ទុកក្នុងពិពិធភណ្ឌស្ថានធំនៅក្រុងឡុនដនអង់គ្លេសក៏មាន សល់អំពីនេះ គេយកទៅលក់ឡាយឡុង គិតជាប្រាក់ប្រហែលជា ១.០៧២.៤០០ រៀល ឯព្រះរាជាភូមានឹងអគ្គមហេសីនឹងព្រះវរជននីមាតាត្រូវនិរទេសទៅនៅស្រុកឥណ្ឌា ។

ប្រទេសភូមានេះមានទំហំដីធំប្រហែលនឹងមហានគរបារាំងសែស ប៉ុន្តែមានចំនួនមនុស្សតិច ប្រហែល ១ ភាគក្នុង ៤ ភាគ នៃបណ្ដាកស្ត្រប្រទេសបារាំង ។

ក្នុងរាង ព.ស. ១៧៤៣ ពួកជាតិតាតារព្យាយាមនឹងលុកលុយប្រទេសភូមាតែមិនសម្រេចឡើយ រហូតមកដល់វេលាអង់គ្លេសមកគ្រប់គ្រងស្រុកភូមាដោយធ្វើសង្គ្រាមមានជ័យជំនះ ហេតុនេះបានជាគ្រឿងភ្លេងតូរ្យតន្ត្រី បែបការកសាង នឹងបែបរបាំកំរែកទាំងឡាយ ទើបគង់ទ្រង់ដូចដើមដដែល ព្រមទាំងគ្រឿងចម្លាក់រចនានឹងបែបគំនូរ ដែលសម្រាប់ប្រើជាគ្រឿងប្រដាប់សម្រាប់ការកសាងផ្សេងៗ ក៏ល្មមជាគំនូរបែបផែនដល់ពួកភូមាជាន់ក្រោយ ព្រោះបែបផែនជាន់ដើមសុទ្ធសឹងតែវិសេសៗ គួរប្រកាន់ជាច្បាប់បានព្រមទាំងបែបសំលៀកបំពាក់ ។

អក្សរសាស្ត្ររបស់ភូមាបានផ្ញើទុកនឹងពុទ្ធសាសនា ។ នេះឯងដែលនាំបណ្ដាលឲ្យកើតបែបសិល្បកម្មគ្រប់ចំពូកឡើង ។ អ្នកតែងសេចក្ដីនេះបានកត់សំគាល់ទុកថា ក្នុងវេលា ៩០ ឆ្នាំតមកនៅវេលាដែលអង់គ្លេសចូលមកគ្រប់គ្រងប្រទេសភូមាហើយ បែបសិល្បកម្មរបស់ភូមា គេនាំគ្នាបោះបង់ចោល ឯផលប្រយោជន៍របស់ស្រុក អង់គ្លេសនាំយកទៅចាយវាយ ដើម្បីសាងមន្ទីរព្យាបាលពេតក្នុងប្រទេសភូមា ហើយសេចក្ដីត្រូវ

ការ របស់រាជការចំពោះការចេះភាសាអង់គ្លេសទើបមានប្រយោជន៍ដល់ក្រ-សួងរាជការ សាលាបង្រៀនភូមាតោងមានបង្រៀនភាសាអង់គ្លេសផង ៗ មិនយូរប៉ុន្មាន នៅទីក្រុងរួមខែត្រក្រៅ សុទ្ធតែមានមន្ទីរពេទ្យបាលរោគ ១ សាលាបង្រៀន ១ គុក ១ ប៉ុស្តិ៍ប៉ូលិស ១ ៗ ឯពួកអ្នកស្រុកដោយច្រើន ជាអ្នករកស៊ីធ្វើស្រែ ជារបរសម្រាប់ទុកបរិភោគផ្ទាល់ខ្លួនផង សម្រាប់លក់ចំណាយបង់ពន្ធជូនរាជការផង លក់ចំណាយទៅទិញសំពត់អាវនិងគ្រឿងប្រដាប់ប្រដាផ្សេង ៗ ដែលខ្លួនត្រូវការផង (តាមទំនងនេះ អ្នកស្រែស្រុកភូមាដូចអ្នកស្រែស្រុកខ្មែរដែរ) ៗ

ស្រុកយ៉ាំងគុងទុកជាក្រុងធំរបស់ភូមា ពីដើមមករាជការប្រទេសភូមាភ្ជាប់នឹងរាជការស្រុកឥណ្ឌា ទើបតែមកដល់ឆ្នាំ ១៩៣៧ ប្រទេសភូមាបានញែកពីគ្នាដាច់ស្រឡះពីប្រទេសឥណ្ឌា ៗ តាមធម្មតា បណ្ដាមហាក្សត្រប្រទេសភូមាទ្រង់សព្វព្រះទ័យមាសពេជ្រណាស់ ហេតុនេះបានជាត្បូងទទឹមដែលជាដុំថ្មមានដំឡៃមាននៅក្នុងស្រុក (ទ្រង់ឲ្យគាស់ក-កាយយកមកធ្វើជាគ្រឿងប្រដាប់ប្រដាផ្សេង ៗ) វត្ថុមានដំឡៃអស់នេះរាជការអង់គ្លេសបានចាត់ចែងឲ្យជីកគាស់យកមកបានច្រើន ដូចជាត្បូងទទឹម អណ្ដូងប្រេងកាត កាត់កាប់ព្រៃឈើដែលមានដំឡៃ ៗ

រួមទាំងដុំថ្មជាលោហធាតុជាតិប្រាក់ សាំងកាសី, សំណ, ស្ពាន់, នីកែល, សំណយ៉ាំងរ៉ង់ និងមាស (បានជាចំនួនច្រើន) ប៉ុន្តែផល

ការរបស់រាជការចំពោះការរេះភាសាអង់គ្លេសទើបមានប្រយោជន៍ដល់ក្រសួងរាជការ សាលាបង្រៀនភូមាតែងមានបង្រៀនភាសាអង់គ្លេសផង ។ មិនយូរប៉ុន្មាន នៅទីក្រុង រួមខែត្រក្រៅ សុទ្ធតែមានមន្ទីរព្យាបាលរោគ ១ សាលាបង្រៀន ១ គុក ១ ប៉ុស្តិ៍ប៉ូលិស ១ ។ ឯពួកអ្នកស្រុកដោយច្រើនជាអ្នករកស៊ីធ្វើស្រែ ជារបរសម្រាប់ទុកបរិភោគផ្ទាល់ខ្លួនផង សម្រាប់លក់ចំណាយបង់ពន្ធជូនរាជការផង លក់ចំណាយទៅទិញសំពត់អាវនិងគ្រឿងប្រដាប់ប្រដាផ្សេង ៗ ដែលខ្លួនត្រូវការផង (តាមទំនងនេះ អ្នកស្រែស្រុកភូមាដូចអ្នកស្រែស្រុកខ្មែរដែរ) ។

ស្រុកយ៉ាំងគុងទុកជាក្រុងធំរបស់ភូមា ពីដើមមករាជការប្រទេសភូមាភ្ជាប់នឹងរាជការស្រុកឥណ្ឌា ទើបតែមកដល់ឆ្នាំ ១៩៣៧ ប្រទេសភូមាបានញែកពីគ្នាដាច់ស្រឡះពីប្រទេសឥណ្ឌា ។ តាមធម្មតា បណ្ដាមហាក្សត្រប្រទេសភូមាទ្រង់សព្វព្រះទ័យមាសពេជ្រណាស់ ហេតុនេះបានជាត្បូងទទឹមដែលជាដុំថ្មមានដំឡៃមាននៅក្នុងស្រុក (ទ្រង់ឲ្យគាស់កកាយយកមកធ្វើជាគ្រឿងប្រដាប់ប្រដាផ្សេង ៗ ) វត្ថុមានដំឡៃអស់នេះរាជការអង់គ្លេសបានចាត់ចែងឲ្យជីកគាស់យកមកបានច្រើន ដូចជាត្បូងទទឹម អណ្ដូងប្រេងកាត កាត់កាប់ព្រៃឈើដែលមានដំឡៃ ។

រួមទាំងដុំថ្មជាលោហធាតុជាតិប្រាក់ សាំងកាសី, សំណ, ស្ពាន់, នីកែល, សំណយ៉ាំងវ៉ង់ និងមាស (បានជាចំនួនច្រើន) ប៉ុន្តែផល

ចំណូលអស់នេះ បានមកជាប្រយោជន៍ប្រទេសភូមាតែមួយភាគតូចទេ ឯផលប្រយោជន៍ជាចំណែកធំពួកការតាក់បញ្ជូនទៅជួយសង្គ្រោះដល់ពួក-ការប្រទេសឥណ្ឌា ដែលទើបតែដាច់ពីគ្នាស្រឡះក្នុងឆ្នាំ ១៩៣៧ នេះឯង ។

ឯចំណុចប្រជាជនជាតិហិណ្ឌូ មានចំនួនណែនណាន់តាន់តាប់ណាស់ សព្វថ្ងៃនេះមានចំនួនច្រើនជាងរាស្ត្រភូមា ដល់ទៅ ១២ ភាគ (1/12) ហើយនៅក្រុងយ៉ាងគុងមានជនជាតិហិណ្ឌូច្រើនជាងជនជាតិភូមាទៅទៀត (ទំនងចិនយួននៅផ្សារក្រុងភ្នំពេញច្រើនជាងជាតិខ្មែរ) ជំនួញជួញប្រែគ្រប់មុខនៅក្នុងកណ្ដាប់ដៃជាតិភូមាតែបន្តិចបន្តួច ក្រៅអំពីនេះនៅក្នុងដៃក្លិង្គទាំងអស់ ។ តាំងអំពីពុទ្ធសករាជ ២៣៩៥ អង់គ្លេសចូលទៅគ្រប់គ្រងប្រទេសភូមា ហើយប្រគល់មុខក្រសួងរាជការឲ្យបរទេស (ក្លិង្គ) កាន់ការក្រសួងរាជការគ្រប់តំណែង ។ ប្រសិនបើរាជការថ្មីប្រទេសភូមាអាចគិតគូរឲ្យបានសម្រេចប្រស្នាធំៗទាំងអស់នេះ ព្រមទាំងជំរឿនការសិក្សាអ្នកស្រុករបស់ខ្លួនឲ្យជឿនលឿនទៅខាងមុខផង ហើយចាត់ចែងកិច្ចការផ្សេងៗដោយខ្លួនឯងបាន រៀបចំជនជាន់កណ្ដាលឲ្យមានការសិក្សាខ្ពស់ឡើងទៀត ទើបធ្វើកិច្ចការផ្សេងៗឲ្យប្រព្រឹត្តទៅបានស្រួល ។

ខធំៗ ដែលពួកក្រុមជំនុំរាជការថ្មីជាតិភូមារៀបចំឲ្យបានសម្រេចនេះ ត្រូវតែរៀបចំធ្វើក្រុងយ៉ាងគុងជាទីក្រុងធំរបស់ប្រទេសភូមា ហើយ

ត្រូវរើសរកកន្លែងមួយដ៏ធំដុំសម្រាប់ធ្វើជំនួញរបស់ប្រទេសជាតិគេទៅ ក្នុងទីបំផុត ត្រូវជួយទំនុកបំរុងបែបបរចនារបស់ជាតិកូមាដោយបង្កើតឲ្យមានសារមន្ទីរមួយ ក្រសួងរៀបចំបុកណាវត្ថុមួយ សាលារចនាមួយ បណ្ណាល័យសម្រាប់ជាតិមួយ ដើម្បីជួយឲ្យមានសេចក្តីក្លាហានដល់ពួកអ្នកតែងរឿងជាជាតិកូមាជំនាន់ក្រោយ ដែលសរសេរពីការងាររបស់កូមាជាន់ដើម ។

លោកអ្នកតែងរឿងនេះបញ្ចប់យោបល់របស់លោក ដោយពាក្យ ១ ម៉ាត់ថា ត្រូវជួយជ្រោមជ្រែងជីវិតវិញ្ញាណជាតិកូមា ឲ្យមានលក្ខណៈបែបភាពជាកូមាគ្រប់បរិបូណ៌ កុំឲ្យទៅជាជាតិប្រឡាំប្រកូវ (ដូចជាសត្វប្រឡាំងកាស) មិនមែនជាជនឧរុប មិនមែនជាជនឥណ្ឌូ មិនមែនជាជនកូមា មុខគួរឲ្យអាណិតណាស់ ដែលពួកនេះជ្រុលគំនិតដើរតាមបែបស៊ីវិល្សមួយ ដែលមិនមែនជារបស់ខ្លួន ។

ត្រូវរើសរកកន្លែងមួយដ៏ធំដុំសម្រាប់ធ្វើជំនួញរបស់ប្រទេសជាតិគេទៅ ក្នុងទីបំផុត ត្រូវជួយទំនុកបំរុងបែបបរចនារបស់ជាតិកូមាដោយបង្កើតឲ្យមានសារមន្ទីរមួយ ក្រសួងរៀបចំបុរាណវត្ថុមួយ សាលារចនាមួយ បណ្ណាល័យសម្រាប់ជាតិមួយ ដើម្បីជួយឲ្យមានសេចក្ដីក្លាហានដល់ពួកអ្នកតែងរឿងជាជាតិកូមាជំនាន់ក្រោយ ដែលសរសេរពីការងាររបស់កូមាជាន់ដើម ៗ

លោកអ្នកតែងរឿងនេះបញ្ចប់យោបល់របស់លោក ដោយពាក្យ ១ ម៉ាត់ថា ត្រូវជួយជ្រោមជ្រែងជីវិតវិញ្ញាណជាតិកូមា ឲ្យមានលក្ខណៈបែបភាពជាកូមាគ្រប់បរិបូណ៌ កុំឲ្យទៅជាជាតិប្រឡាំប្រកូវ (ដូចជាសត្វប្រឡាំងកាស) មិនមែនជាជនអឺរុប មិនមែនជាជនឥណ្ឌូ មិនមែនជាជនកូមាមុខគួរឲ្យអាណិតណាស់ ដែលពួកនេះជ្រុលគំនិតដើរតាមបែបស៊ីវិឡៃមួយ ដែលមិនមែនជារបស់ខ្លួន ៗ



២៣ — អំពីការល្បួងលួងលោមក្រុងមារ

# ហោរាសាស្ត្រនឹងព្រះពុទ្ធសាសនា

របស់ហ្វនសាកនុប្រពន្ធ

ខេមររង្សី

ប្រែចេញពីទស្សនាវដ្តីពុទ្ធសាសនាថៃ

(តនឹងចប់)

# បាឋកថាលើកទី ២

(សេចក្ដីតមក)

បាឋកថាលើកទី ១ ខ្ញុំបានថ្លែងអំពីព្រហ្មលិខិតដែលមនុស្សអ្នកកាន់សាសនាព្រាហ្មណ៍តែងជឿប្រកាន់ថា ទ្រង់បានដាក់កំរិតល្អអាក្រក់លើរូបមនុស្សគ្រប់រូប តែខាងពុទ្ធសាសនាប្រកាន់ថា ផលល្អអាក្រក់កើតអំពីកម្មរបស់សត្វ កម្មនេះតែងជូនផលដល់ម្ចាស់កម្ម ដោយនានាវិធី គឺឲ្យផលមួយរំពេច ១ ឲ្យផលបន្ទាប់គ្នានេះ ១ ឲ្យផលបន្ទាប់តទៅទៀតជាច្រើនរយៈ ១ មិនឲ្យផលគឺសាបសូន្យទៅឬរម្ងាប់ទៅឯង ១ ៗ មនុស្សគ្រប់រូបក្នុងលោកនេះនៅក្រោមបង្គាប់នៃធម្មជាតិ ដោយអាស្រ័យកម្មជាកំឡាំងជូន មនុស្សទើងបានអាក្រក់ល្អស្រេចហើយតែកម្ម ឬអំពើរបស់ខ្លួនឯង តែកាលបើពិនិត្យពិចារណាមើលតាមទំនងនេះហើយ នឹងឃើញបានថា “ធម្មជាតិជាធំជាង» ព្រោះកម្មគ្រាន់តែជាកំឡាំងជូនតែម្យ៉ាង ឯធម្មជាតិនោះមានកំឡាំងជាអំណាចបង្គាប់ដាច់ខាត ក្នុងការដែលធ្វើមនុស្សឲ្យបានទទួលផលកម្មឬមិនបាច់... បើមិនដូច្នេះទេ មនុស្សធ្វើល្អទើងបានទទួលផលល្អមួយរំពេច ឯសេចក្ដីអាក្រក់ក៏ឲ្យផលអាក្រក់មួយរំពេចដែរ ៗ

រឿងនេះមានសេចក្ដីប្រៀបដូចមេពពកល្អិត ៗ នៅក្នុងអាកាសដែលសន្មតថាជាតួកម្ម ដែលអណ្ដែតធ្វេធ្វាទៅមកជុំវិញខ្លួនយើង ហើយចាំ

ប្រទូសកាយយើងគ្រប់វិនាទី ធម្មជាតិប្រៀបដូចជាកំឡាំងតទល់នៃកងកាយ បើមានកំឡាំងរឹងប៉ឹងជាងមេរោគៗក៏មិនអាចធ្វើអន្តរាយដល់កងកាយយើងបាន ថែមទាំងស្លាប់ឬអន្តរាយដោយសារវាមកប៉ះទង្គិចនឹងកងកាយយើងក៏មានច្រើនជាអនេក ធម្មជាតិនេះរមែងមានឥទ្ធិពល (Infleuence) ក្នុងការដឹកនាំមនុស្សឲ្យបានទទួលផលឬមិនបាន ឬឲ្យបានទទួលតែបន្តិចឬច្រើនយ៉ាងបានស្រេចតែសន្ទុះឥទ្ធិពលនោះៗ ហេតុនេះ ការរៀនឲ្យដឹងស្គាល់ផលរបស់កម្ម ទើបគួរតែរៀនឲ្យស្គាល់ឥទ្ធិពលនៃធម្មជាតិ ហើយការរៀនឲ្យស្គាល់ឥទ្ធិពលនៃធម្មជាតិនោះ ក៏គឺការរៀនលោកសាស្ត្រនេះឯង ។

## (លើកទី ៣ តមក)

ព្រះពុទ្ធសាសនាសំដែងថា កម្មតែងចែកសត្វទាំងឡាយឲ្យមានបែបភាពផ្សេងៗគ្នា ពោលគឺកម្មដែលបុគ្គលធ្វើទុកពីជាតិមុន ជាបុណ្យឬជាបាបក៏ដោយ តែងជូនផលដល់បុគ្គលនោះក្នុងជាតិនេះ ក៏ផលនៃកម្មក្នុងអតីតនុះជូនបុគ្គលនោះឲ្យមកចាប់ជាតិក្នុងបច្ចុប្បន្ននេះ សំដែងឲ្យឃើញជាក់ច្បាស់ដោយផ្កាយនក្ខត្តឫក្សទាំងឡាយ គឺបុគ្គលដែលមកចាប់ជាតិនេះមានភ័ព្វឬឥតភ័ព្វ ការដែលផ្កាយព្រះគ្រោះសំដែងឲ្យឃើញហេតុអ្វីតែងប្រព្រឹត្តទៅតាមចារិកនៃកម្មល្អអាក្រក់ ជូនផលដល់មកជាតិនេះ តាម

ប្រទូសកាយយើងគ្រប់វិនាទី ធម្មជាតិប្រៀបដូចជាកំឡាំងតទល់នៃកងកាយ បើមានកំឡាំងរឹងប៉ឹងជាងមេរោគៗក៏មិនអាចធ្វើអន្តរាយដល់កងកាយយើងបាន ថែមទាំងស្លាប់ឬអន្តរាយដោយសារមកប៉ះទង្គិចនឹងកងកាយយើងក៏មានច្រើនជាអនេក ធម្មជាតិនេះរមែងមានឥទ្ធិពល (Infleuence) ក្នុងការដឹកនាំមនុស្សឲ្យបានទទួលផលឬមិនបាច់ ឬឲ្យបានទទួលតែបន្តិចឬច្រើនយ៉ាងបានស្រេចតែសន្ទុះឥទ្ធិពលនោះៗ ហេតុនេះ ការរៀនឲ្យដឹងស្គាល់ផលរបស់កម្ម ទើបតោងតែរៀនឲ្យស្គាល់ឥទ្ធិពលនៃធម្មជាតិ ហើយការរៀនឲ្យស្គាល់ឥទ្ធិពលនៃធម្មជាតិនោះ ក៏គឺការរៀនហោរាសាស្ត្រនេះឯង ៗ

## (លើកទី ៣ តមក)

ព្រះពុទ្ធសាសនាសំដែងថា កម្មតែងចែកសត្វទាំងឡាយឲ្យមានបែបភាពផ្សេងៗគ្នា ពោលគឺកម្មដែលបុគ្គលធ្វើទុកពីជាតិមុន ជាបុណ្យឬជាបាបក៏ដោយ តែងជូនផលដល់បុគ្គលនោះក្នុងជាតិនេះ ក៏ផលនៃកម្មក្នុងអតីតនុ៎ះជូនបុគ្គលនោះឲ្យមកចាប់ជាតិក្នុងបច្ចុប្បន្ននេះ សំដែងឲ្យឃើញជាក់ច្បាស់ដោយផ្កាយនក្ខត្តឫក្សទាំងឡាយ តើបុគ្គលដែលមកចាប់ជាតិនេះមានភ័ព្វឬឥតភ័ព្វ ការដែលផ្កាយព្រះគ្រោះសំដែងឲ្យឃើញហេតុអ្វីតែងប្រព្រឹត្តទៅតាមចារិកនៃកម្មល្អអាក្រក់ ជូនផលដល់មកជាតិនេះ តាម

ទំនងនេះ ផ្កាយព្រះគ្រោះមិនមែនជាអ្នកបណ្ដាលផលទេ តែជាអ្នកបង្អុលប្រាប់ផលកម្មឲ្យដឹងជាក់ច្បាស់ប៉ុណ្ណោះ ។

គម្ពីរ « លោកធាតុ » ជាតម្រាហោរាសាស្ត្រ ១ ពោលកាប់រងសេចក្ដីដែលពោលមកនេះ ។

ហេតុដែលវិជ្ជាហោរាសាស្ត្រ មានគុណឧបការៈជាចំណែកអនាគតង្សញ្ញាណ ដើម្បីជាប្រយោជន៍ក្នុងការប្រុងប្រៀបឲ្យទាន់កាលសម័យ ។ ប្រការមួយទៀត មានលោកអ្នកខ្លះឬមានចំនួនជាច្រើននាក់ដែលមិនទាន់ស្គាល់សេចក្ដីពក់ជ្រៅ ក្រាស់ស្ដើងពិតប្រាកដនៃហោរាសាស្ត្រ ច្រើនតែពោលបន្ដុះថា វិជ្ជានេះជាតិរច្ឆានវិជ្ជា ហើយពោលអាងថាវិជ្ជានេះ ជាទំនាស់នឹងពុទ្ធសាសនា ដែលបញ្ញត្តឲ្យមនុស្សជឿកម្ម មិនឲ្យជឿមង្គល ហាមមិនឲ្យភិក្ខុសាមណេររៀនវិជ្ជានេះ អ្នករៀនទុកជាល្មើសខុសនឹងពុទ្ធៈបញ្ញត្តិ ពាក្យពោលអស់នេះជាពាក្យប្រកបដោយអគតិ ហេតុនេះទើបគួរនាំយកព្រះពុទ្ធដីកាដែលជាព្រះពុទ្ធានុញ្ញាតឲ្យភិក្ខុបរិសទ្យសិក្សាហោរាសាស្ត្រមកសំដែងដល់អ្នកស្ដាប់ក្នុងទីនេះ សឹងមានសេចក្ដីប្រាកដក្នុងគម្ពីរចន្ទសុរិយគតិទីបនីដីកាវិនយវិនិច្ឆ័យ ដូចមានសេចក្ដីប្រែដូច្នេះ អាចារ្យចំពួកខ្លះអាស្រ័យហេតុដែលខ្លួនមិនបានដឹងក្រសែអធិប្បាយនៃដីកាវិន័យ ក៏លើកទោសតិះដៀលថា ធ្វើជាសមណៈហើយ ដូចម្ដេចមកនាំគ្នារៀននក្ខត្តឫក្ស

ជាពាហិរវិជ្ជាដូច្នេះ ព្រះគម្ពីរនេះជាទីញុំាងពាក្យគរហានិន្ទាឲ្យរលត់សាប សូន្យអស់ទៅ ៗ ឯសេចក្ដីអធិប្បាយនៃដីកាវិន័យនោះមានមូលហេតុមក ពីភិក្ខុសង្ឃ នាំគ្នាទៅចំរើនសមណធម៌នៅក្នុងព្រៃជាអារញ្ញិកសេនាសនៈ មានពួកចោរ ១ ពួកមកសួរថា ថ្ងៃនេះ ព្រះចន្ទប្រកបដោយនក្ខត្តឫក្សដូច ម្ដេច ៗ ពួកភិក្ខុប្រាប់ថា អាត្មាមិនដឹងទេ ទើបពួកចោរថា ជនទាំងនេះ មិនមែនជាសមណៈទេ បានជាមិនស្គាល់នក្ខត្តឫក្ស ប្រហែលជាពួកចោរមក លាក់ខ្លួនពួនសម្ងំនៅទេដឹង? លុះពោលដូច្នេះហើយ ចោរទាំងឡាយក៏នាំ គ្នា[illegible]ភិក្ខុអស់នោះឲ្យឈឺ [illegible]បៀតបៀនទៅ ៗ រឿងនេះបានជ្រាបដល់ព្រះដ៏មានព្រះភាគជាម្ចាស់ ព្រះអង្គមានព្រះពុទ្ធ-ដីកាត្រាស់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលទៅចំរើនសមណធម៌ក្នុងអារញ្ញិកសេនាសនៈ រៀនសូត្រឲ្យស្គាល់នក្ខត្តឫក្ស ទោះរៀនបានទាំងអស់ក្ដី ដោយឯកទេស ក្ដី សម្រាប់ជាអារញ្ញិកវត្ត ដើម្បីរក្សាខ្លួនឲ្យផុតពីចោរន្តរាយ... ៗ

ជាពាហិរវិជ្ជាដូច្នេះ ព្រះតម្រិះនេះជាទីញុំាងពាក្យគរហានិន្ទាឲ្យរលត់សាបសូន្យអស់ទៅ ៗ ឯសេចក្ដីអធិប្បាយនៃដីកាវិន័យនោះមានមូលហេតុមកពីភិក្ខុសង្ឃ នាំគ្នាទៅចំរើនសមណធម៌នៅក្នុងព្រៃជាអារញ្ញិកសេនាសនៈ មានពួកចោរ ១ ពួកមកសួរថា ថ្ងៃនេះ ព្រះចន្ទប្រកបដោយនក្ខត្តឫក្សដូចម្ដេច ៗ ពួកភិក្ខុប្រាប់ថា អាត្មាមិនដឹងទេ ទើបពួកចោរថា ជនទាំងនេះមិនមែនជាសមណៈទេ បានជាមិនស្គាល់នក្ខត្តឫក្ស ប្រហែលជាពួកចោរមកលាក់ខ្លួនពួនសម្ងំនៅទេដឹង? លុះពោលដូច្នេះហើយ ចោរទាំងឡាយក៏នាំគ្នា[illegible]ភិក្ខុអស់នោះឲ្យឈឺ [illegible] ៗ

រឿងនេះបានជ្រាបដល់ព្រះដ៏មានព្រះភាគជាម្ចាស់ ព្រះអង្គមានព្រះពុទ្ធដីកាត្រាស់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលទៅចំរើនសមណធម៌ក្នុងអារញ្ញិកសេនាសនៈ រៀនសូត្រឲ្យស្គាល់នក្ខត្តឫក្ស ទោះរៀនបានទាំងអស់ក្ដី ដោយឯកទេសក្ដី សម្រាប់ជាអារញ្ញិកវត្ត ដើម្បីរក្សាខ្លួនឲ្យផុតពីចោរន្តរាយ... ៗ



២៤ — អំពីបុត្រីនៃក្រុងមារ

## ពុទ្ធប្រវត្តិពិន

តពីខ្សែ ៦ មក

## ២០ - អំពីនាងសុជាតាថ្វាយមធុបាយាស

នៅវេលាដែលនាងសុជាតាពោលលាបំណន់នោះ ជាវេលាដែលព្រះពោធិសត្វនឹងបានត្រាស់ជាព្រះពុទ្ធពេញបរិបូណ៌ ទើបនាងសុជាតាធ្វើមធុបាយាសដាក់ថាសនាំមកថ្វាយព្រះអង្គ ។

## ២១ – អំពីព្រះពោធិសត្វទ្រង់ស្រង់ទឹកដំបូង

ព្រះពោធិសត្វស្ដេចចុះទៅក្នុងស្ទឹង ដើម្បីឲ្យត្រជាក់សព្វព្រះសពាង្គកាយ ។ ខណៈនុះឯង ធីតានៃស្ដេចនាគបាននាំយកអាសនៈមួយពីពិកពនាគឡើងមកថ្វាយព្រះអង្គ (ត្រង់កូនស្រីស្ដេចនាគយកអាសនៈមកថ្វាយនេះមិនមានសំដែងទុកក្នុងគម្ពីរហីនយានទេ) ។

## ២២ – អំពីបាច់ស្មៅរបស់ស្វស្ដិកព្រាហ្មណ៍

មានព្រាហ្មណ៍ម្នាក់ឈ្មោះស្វស្ដិកៈ បានប្រូតស្មៅថ្មីៗ មានពណ៌ខ្ចីខៀវស្រងាត់ប្រមូលចងក្រងជាបាច់រួចស្រេច ស្រាប់តែក្រឡេកឃើញព្រះពោធិសត្វ ទើបបង្អោនបាច់ស្មៅថ្វាយឲ្យទ្រង់ក្រាលគង់ ។

## ២៣ – អំពីការល្បួងលួងលោម

- ពួកកូនស្រីនៃក្រុងមារ នាំគ្នាដំណែងរាងកាយជានាងស្រីក្រមុំរូបស្រស់ប្រិមប្រិយហើយចូលទៅគាល់ជិតព្រះតថាគតតែម្តង ។.

## ២៤ – អំពីបុត្រីនៃក្រុងមារ

ព្រះតថាគតមិនទ្រង់ទតមើលសោះឡើយ ហើយទ្រង់បំប្លែងស្ត្រីអស់នោះ ឲ្យទៅជាស្រីចាស់ជរាទៅវិញ មុខគួរឲ្យអាណោចអាធម្មណាស់ ។

(មានតទៅទៀត)

## ២៣ – អំពីការល្បួងលួងលោម

ពួកកូនស្រីនៃក្រុងមារ នាំគ្នាដំណែងរាងកាយជានាងស្រីគ្រប់រូប ស្រស់ប្រិមប្រិយ ហើយចូលទៅគាល់ជិតព្រះតថាគតតែម្ដង ។

## ២៤ – អំពីបុត្រីនៃក្រុងមារ

ព្រះតថាគតមិនទ្រង់ទតមើលសោះឡើយ ហើយទ្រង់បំប្លែងស្ត្រីអស់នោះ ឲ្យទៅជាស្រីចាស់ជរាទៅវិញ មុខគួរឲ្យអាណោចអាធម្មណាស់ ។

(មានតទៅទៀត)



អំពីគ្រូមីលរេប៉ះ  ល្បងចិត្តមីលរេប៉ះ

# ប្រវត្តិមីលរេប៉ះ

(តពីខ្សែ ៦ មក)

ទើបមីលរេប៉ះជំរាបថ្វាយលោកអ្នកប្រាជ្ញនោះថា ខ្ញុំបានធ្វើអំពើបាបមកជាច្រើន ៗ ឯលោកម៉ារប៉ះក៏និយាយសន្យាថានឹងទំនុកបំរុងមីលរេប៉ះឲ្យបានដល់ថ្នាក់ពោធិ (សេចក្តីត្រាស់ដឹងតទៅ) ហើយបានល្បងចិត្តមីលរេប៉ះជាច្រើនវិធី ដូចជាបង្គាប់ឲ្យធ្វើប៉ម ១ ឡើងហើយឲ្យរាយរំលាយទៅវិញ ហើយបង្គាប់ឲ្យកសាងឡើងវិញទៀត (មើលរូបទំព័រ ៨១) ។ លុះក្នុងសម័យតមក មីលរេប៉ះបានបញ្ចូនចិត្តចូលទៅក្នុងផ្លូវពេះដឹងក្រោយដែលបានព្យាយាមប្រតិបត្តិដោយលំបាកវេទនា ៗ នៅថ្ងៃមុនដែលលោកមីលរេប៉ះចូលមកនៅសិក្សាក្នុងសំណាក់លោកម៉ារប៉ះនោះ លោកម៉ារប៉ះបានយល់សប្តិក្នុងយប់មួយថា មីលរេប៉ះនឹងចូលមកនៅហើយនឹងប្រតិបត្តិតាមផ្លូវព្រះពុទ្ធសាសនាយ៉ាងម៉ឺងម៉ាត់ ៗ កាលណោះមីលរេប៉ះបានព្យាយាមខំចំរើនភាវនាកម្មប្រកបដោយបីតិនឹងសុខកាយនឹងសុខចិត្ត ៗ លុះលោកមីលរេប៉ះនៅនឹងអាចារ្យជាច្រើនឆ្នាំទៅ ក៏គិតឃើញថា គួរត្រឡប់ទៅស្រុកកំណើតវិញ ទើបលោកជំរាបលាលោកគ្រូ ៗ នោះពោលថា "ឱកូនអើយដំណើរដែលកូនចេញចោលឪពុកទៅនេះស្មើនឹងធ្វើឲ្យបេះដូងឪពុកប្រេះ

ឆ្ងាយ” ទើបលោកមានប្រសាសន៍ទៅនឹងភរិយារបស់លោកថា “ចូរនាង រៀបចំដំណើរមើលរបេះឲ្យបានស្រួលតាមផ្លូវកុំឲ្យខ្វះខាត ហើយយើងត្រូវតែអនុញ្ញាតឲ្យគេទៅតាមប្រាថ្នា” ។

(មានតទៅទៀត)

ក្លាយ" ទើបលោកមានប្រសាសន៍ទៅនឹងកិរិយារបស់លោកថា "ចូរនាងរៀបចំដំណើរមើលរបេះឲ្យបានស្រួលតាមផ្លូវកុំឲ្យខ្វះខាត ហើយយើងត្រូវតែអនុញ្ញាតឲ្យគេទៅតាមប្រាថ្នា" ។

(មានតទៅទៀត)